**BMI0154**

ឈ្មោះ ប៉ូ បណ្ឌិត ភេទប្រុស អាយុ៦៣ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ “ប្រធានក្រុមកងភ្ជួរ”

សព្វថ្ងៃរស់នៅភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា

០១:១០:៣១

២៧ទំព័រ

ដារ៉ា : អញ្ចឹងខ្ញុំចាប់ផ្តើមថតសម្លេងពូ?

បណ្ឌិតៈ បាទ!

ដារ៉ា : ដោយសាពូមានការអនុញ្ញាតហើយ ដំបូងខ្ញុំចង់សួរនាំបញ្ជាក់បន្តិចអំពីឈ្មោះរបស់ពូ?

បណ្ឌិតៈ ខ្ញុំឈ្មោះ ប៉ូ បណ្ឌិត ។

ដារ៉ា : លោកពូអាយុប៉ុន្មានឆ្នាំហើយ?

បណ្ឌិតៈ ខ្ញុំអាយុ៦៣ឆ្នាំ ។

ដារ៉ា : អាយុ៦៣ឆ្នាំហើយណោះ ។ ហើយនៅភូមិអី ឃុំអី?

បណ្ឌិតៈ ភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

ដារ៉ា : ហើយស្រុកកំនើតរបស់ពូ?

បណ្ឌិតៈ នៅភូមិនេះ ។

ដារ៉ា : ភូមិកណ្តាលហ្នឹងដែរ?

បណ្ឌិតៈ បាទ!

ដារ៉ា : ហើយពូមានគ្រួសារឈ្មោះអីដែរ?

បណ្ឌិតៈ ធិប យុភួន ។

ដារ៉ា : ធិប?

បណ្ឌិតៈ ធិប យុភួន ។

ដារ៉ា : ធិប យុភួន គ្រួសារពូអាយុប៉ុន្មានឆ្នាំដែរ?

បណ្ឌិតៈ អាយុ៥៦ឆ្នាំ ។

ដារ៉ា : ពូមានកូនចៅប៉ុន្មាននាក់?

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. • P.O.Box 1110 • Phnom Penh • Cambodia
t (855-23) 211-875 • f (855-23) 210-358 • dccam@online.com.kh • www.dccam.org

បណ្ឌិតៈ   ៨នាក់ ។

ដារ៉ា :   រៀបរាប់បានទេ?

បណ្ឌិតៈ   កូនខ្ញុំបងឈ្មោះ សឿន គង់, ២ សឿន សំអាន, ៣ សឿន សិន, ៤ សឿន សេរី, សឿន ហីង មុន ស្រីមុនបាន សឿន សុភាព ស្រី, សឿន សេរី, សឿន ទេវីន, សឿន វិសុទ្ធ, សឿន សុភាព ។

ដារ៉ា :   អញ្ចឹងក្នុងចំណោមកូន៨នាក់ហ្នឹងប្រុសប៉ុន្មានស្រីប៉ុន្មាន?

បណ្ឌិតៈ   ប្រុស៤ ស្រី៤ ។

ដារ៉ា :   ៤ស្មើពូណោះ?

បណ្ឌិតៈ   បាទ!៤ស្មើ ។

ដារ៉ា :   ហើយនៅរស់រានមានជីវិតទាំងអស់?

បណ្ឌិតៈ   នៅរស់ទាំងអស់ ។

ដារ៉ា :   ហើយកូនប៉ុន្មាននាក់ដែលកើតមុន?

បណ្ឌិតៈ   មុនប៉ុល ពត មុនៗ សម័យលន់ នល់កើតកូនបងមួយស្រី សម័យ៧៨ជិតចប់កូនបានមួយទៀតប្រុស ។

ដារ៉ា :   ចឹងបានន័យថាលោកពូបានគ្នាជាគ្រួសារហ្នឹងមុនខ្មែរក្រហម?

បណ្ឌិតៈ   បាទ! មុនខ្មែរក្រហម ដើមឆ្នាំ១៩៧៤ ។

ដារ៉ា :   ដើមឆ្នាំ៧៤ណោះ ។ ហើយពូបានរៀនបានសូត្រអីដែរ?

បណ្ឌិតៈ   បានដែរ គ្រាន់តែមើលបាននិងសរសេរបាន ។

ដារ៉ា :   ពូរៀនបានត្រឹមថ្នាក់ទីប៉ុន្មាន?

បណ្ឌិតៈ   ពីដើមម៉ិញខ្ញុំរៀនថ្នាក់ទី៧ដែរប៉ុនមិនសូវបានបេះទេរឿងអក្សរអី គ្រាន់ថាអាចមើលបានសរសេរបាន ។

ដារ៉ា :   ថ្នាក់ទី៧ហ្នឹងចង់ចូលទៅ គេហៅថាប្រឡងស៊ឺវិការ?

បណ្ឌិតៈ   បាទៗ! ប្រឡងស៊ឺវិការ ថ្នាក់ឧត្តមដ្ឋាន ។

ដារ៉ា :   បានប្រឡងហើយនៅ?

បណ្ឌិតៈ   បាន ។

ដារ៉ា :   ប្រឡងជាប់ទេ?

បណ្ឌិតៈ   អត់ទេធ្លាក់ ។

ដារ៉ា : អរ! ធ្លាក់ទេ?

បណ្ណេតៈ ខ្ញុំសម័យនោះកូនក្រដែរ ហើយកូនកុំព្រាអត់មានម្ដាយ ខ្ញុំនៅអាយុ១៣-១៤ អរ! ១៦ឆ្នាំ ។

ដារ៉ា : ចុះឪពុកពូឈ្មោះអីដែរ?

បណ្ណេតៈ ប៉ូ សឿន ។

ដារ៉ា : ប៉ូ សឿន ។ ហើយគាត់ស្លាប់ឬរស់?

បណ្ណេតៈ ស្លាប់ហើយ ។

ដារ៉ា : ស្លាប់យូរហើយអ្ហេះ?

បណ្ណេតៈ ស្លាប់សម័យលន់ នល់ ។

ដារ៉ា : ចុះម្ដាយ?

បណ្ណេតៈ ម្ដាយស្លាប់យូរហើយ វ៉ែន ធឿង ស្លាប់តាំងពីខ្ញុំអាយុ១៣ ។

ដារ៉ា : វ៉ែន ធឿង អញ្ចឹងអ្ហេះ?

បណ្ណេតៈ បាទ!

ដារ៉ា : កាលពូរៀនថ្នាក់បឋមសិក្សារៀននៅសាលាណា?

បណ្ណេតៈ នេះសាលានេះ ។

ដារ៉ា : ហៅសាលាអីហ្នឹង?

បណ្ណេតៈ សាលាព្រះនេត្រព្រះ ។

ដារ៉ា : ហៅសាលាអីគេហ្នឹង?

បណ្ណេតៈ ព្រះនេត្រព្រះដែរ ហៅសាលាបឋមសិក្សាព្រះនេត្រព្រះ នៅភូមិកណ្ដាលហ្នឹង ។

ដារ៉ា : នៅក្នុងភូមិហ្នឹងពូណោះ?

បណ្ណេតៈ បាទ!

ដារ៉ា : ហើយចុះពេលដែលមានរដ្ឋប្រហារឆ្នាំ៧០អីហ្នឹង?

បណ្ណេតៈ រដ្ឋប្រហារឆ្នាំ៧០ខ្ញុំនៅសេរីសោភ័ណ ។

ដារ៉ា : នៅស្រុកណា?

បណ្ណេតៈ បាទ! សេរីសោភ័ណ ពួកខ្មែរក្រហមគេវ៉ៃខ្លាំងទៅយើងត្រូវគេចទៅនៅសេរីសោភ័ណម៉ារយៈទៅ ចប់ទៅបានម៉ោណេះវិញ ។

ដារ៉ា : ពេលហ្នឹងពួកកខ្មែរក្រហមកាន់កាប់នៅក្នុងភូមិនេះនៅ?

បណ្ណេតៈ ទេមិនទាន់កាន់ទេ ពេលវ៉ៃខ្វាំងខ្ញុំទៅនៅសេរីសោភ័ណនៅតែយើងកាន់ នៅតែខាងលន់ នល់គ្រប់គ្រង ទាល់តែចប់ថ្ងៃ១៧មេសា ។

ដារ៉ា : អញ្ចឹង!

បណ្ណេតៈ ទាល់តែចប់១៧មេសាបានវាឲ្យប្រជាជនចេញពីសេរីសោភ័ណម៉ោ យើងម៉ោស្រុកកំនើតម៉ោបានតែ៤-៥ រយៈពេលប៉ុន្មាន ៣ថ្ងៃវាជម្លៀសចេញឲ្យទៅនៅវាលណោះ ។ ទៅនៅ ៧ថ្ងៃវាឲ្យចូលភូមិវិញ មិនបានចូលភូមិទេ មិនបានចូលផ្ទះខ្លួនឯងទេ ឲ្យទៅនៅដីតាមព្រៃណោះ ។

ដារ៉ា : តាមវាលដែលសំដៅម៉ិញហ្នឹងគេហៅកន្លែងអី?

បណ្ណេតៈ វាលស្រែកំបោរស្រែះ ខាងត្បូងភ្នំស្រែះ ជម្លៀសចេញម៉ោដឹងបូងទៅនៅខាងត្បូងភ្នំស្រែះ ខាងជើងភ្នំស្រែះនោះ ទៅនៅហ្នុងវាចាប់មនុស្សវ៉ៃខ្លះដែរ បើសិនជាមានជំទប់មានអី មានបងប្អូនជំទប់ កូនជំទប់ ហើយនិងមាននិន្នាការដែលវាសម្រាប់ ដូចមានទាក់ទិនដូចជានេះអីវាចាប់វ៉ៃចោលបណ្តោយ វាវ៉ៃទាំងកូនក្មេងប៉ុនៗនេះ ។ កូនជំទប់នោះវាវ៉ៃកូនជំទប់មួយក្រមុំវាបាញ់ ហើយកូនតូចៗបីបួនបណ្តើរវ៉ៃ ហើយខ្ញុំនៅអីវាលស្រែទេ ។ ហើយ បងខ្ញុំមួយគ្រាន់តែចប់ភ្លាមវាតាមវ៉ៃកាលនៅស្វាយ ងាប់កូនប្រុស៣នាក់ ជីដូនមួយអ្នាសកាលពីដើមឡើយគាត់ធ្វើដែរ កាលពីសម័យសង្គមរាស្រ្តនិយមគាត់ធ្វើប៉ូលីសប៉ុនគាត់ពាក់អាស្តង់ កាលពីសម័យនោះធំណាស់ណា ត្រួត២-៣ស្រុក កាលនោះមង្គលបុរី សេរីសោភ័ណ ភ្នំស្រុក ។ ហើយដល់ពេលសម័យលន់ នល់គាត់វែកសេចូលទាហានគាត់ពាក់សក្តិ៣...... ដល់អញ្ចឹងទៅប្តីគាត់គេ សម័យនោះគេឲ្យគាត់ទទួលបន្ទុក ៣ស្រុក ដល់ពេលនេះទៅគាត់ត្រូវពួកវា ពេលចប់ទៅវាឲ្យយកទៅសម្លាប់ចោលអស់ទៅ ។ កូនគាត់ជម្លៀសម៉ោណោះ ថាម៉ោស្រុកកំនើតគេតាមចាប់សម្លាប់អស់ កូនប្រុស៧៨នាក់ ។

ដារ៉ា : ជាបងបង្កើតម៉ង?

បណ្ណេតៈ បងជីដូនមួយ ។

ដារ៉ា : ឈ្មោះអីគេពូ?

បណ្ណេតៈ ឈ្មោះ សារួន ហើយបងប្រុស.... រឿង រឿន សព្វថ្ងៃនៅកូនគាត់មួយនៅស្វាយ ។

ដារ៉ា : ឈ្មោះ រឿង រឿន ហ្នឹងអ្ហេះដែលត្រូវជាបងជីដូនមួយរបស់លោកពូ?

បណ្ណេតៈ បាទ! ជីដូនមួយទាំងពីរនាក់ ខាងនេះក៏ជីដូនមួយ ខាងឪក៏ជីដូនមួយ ខាងឪពុក គាត់ទាំងពីរនាក់ជាប់ ។

ដារ៉ា : ហើយពេលដែលខ្មែររំដោះបានភ្លាមវាតាមរក?

បណ្ឌិត: តាមរកចាប់វៃ ។

ដារ៉ា : ហើយចាប់បាននៅម្ដុំណាវិញ?

បណ្ឌិត: អ្ហូ! ចូលម៉ោដល់នេះហើយ ហៅម៉ោយកម៉ោកត់ប្រវត្តិរូបអីហើយទៅយកទៅវៃចោលនៅជើងភ្នំ ។

ដារ៉ា : ជើងភ្នំអីគេ?

បណ្ឌិត: ជើងភ្នំព្រនេត្រព្រះ ។

ដារ៉ា : ជើងភ្នំព្រះនេត្រព្រះ?

បណ្ឌិត: ហើយយកដោយទាំងមាសទាំងប្រាក់ ហើយវៃដោយទាំងកូនផ្ទះនេះមួយ វៃជុំគ្នា ។

ដារ៉ា : គ្រួសារហ្នឹងឈ្មោះអីគេ?

បណ្ឌិត: ពិន វ៉ាន់ស៊ី ខាងត្បូងផ្ទះខ្ញុំចាស់ ។

ដារ៉ា : ពិន វ៉ាន់ស៊ី?

បណ្ឌិត: ហ្នឹងអាពតយកទៅសម្លាប់ នៅកូនស្រីគាត់មួយ ខ្ញុំបានដើរទៅឃើញ តាមមើលពីលើកុដិព្រោះខ្លាចដែរហ្នឹង ។

ដារ៉ា : អញ្ចឹងការសម្លាប់នេះចាប់ផ្ដើមមានតាំងពីពេលខ្មែរក្រហមទទួលបានជ័យជម្នះ ថ្ងៃទី១៧មេសាម៉ោ?

បណ្ឌិត: បាទ!

ដារ៉ា : កាលហ្នុងពូ ម៉ាថ្ងៃ១៧មេសាហ្នឹងផ្ទាល់ម៉ងគឺថាពួកខ្មែរក្រហមខាងណាពូ?

បណ្ឌិត: ពួកខាងខ្មែរក្រហម អ្នកដែលគេក្ដាប់នេះថាពួកខត្តរ ពួកខត្តរពួកខាងយើងនេះហៅខត្តរ ។

ដារ៉ា : ខត្តរឬពាយ័ព្យ?

បណ្ឌិត: ពាយ័ព្យៗ ពួកខាងតានេះ!

ដារ៉ា : តាញឹម?

បណ្ឌិត: តាញឹមៗ រស់ ញឹម នៅក្ដាប់ហ្នឹង មេតំបន់ ម៉ោបានប៉ុ ហឹង តំបន់៥ណា ដល់ម៉ោបានភូមិភាគឈ្មោះ ញឹម ភូមិភាគ រស់ ញឹម ហើយដល់នេះតា ហឹង នៅតំបន់៥ ។ បានមួយទៀតប៉ុ ដាល នោះយើងគ្រាន់តែម៉ោតាមបក្កតាមលំដាប់តាមខេត្ត ។

ដារ៉ា : ហ្នឹងតំបន់ទេណោះអ៊ំ តំបន់៥?

បណ្ឌិត: បាទ! ប្រធានតំបន់៥ ហើយសម័យស្ទីបស្ទឹម អរ! សម័យពាយ័ព្យ ។

ដារ៉ា : ហើយនៅតំបន់៥ នៅក្នុងស្រុកព្រះនេត្រព្រះយើងម៉ង?

បណ្ឌិតៈ ព្រះនេត្រព្រះៗ បាទតំបន់៥ព្រះនេត្រព្រះ ភ្នំស្រុក សេរីសោភ័ណ ។

ដារ៉ា : ៣ស្រុកហ្នឹងនៅក្នុងតំបន់៥ ?

បណ្ឌិតៈ បាទ!

ដារ៉ា : ហើយមាន ហឹង ជាប្រធានតំបន់?

បណ្ឌិតៈ បាទ! នោះសម័យយើងចាប់ពី៧៥ ។ រំដោះបានពីរបី ចាប់ពីថ្ងៃ១៧មេសាម៉ោចាប់វាក្តាប់បានម៉ោម៉ាខែជាងម៉ោ ជម្លៀសប្រជាជននៅតាមផ្សារនៅតាមភូមិកំនើតហ្នឹងផ្ទេរទៅភូមិមួយទៅភូមិមួយ ។

ដារ៉ា : អញ្ចឹងពេលលោកពូដែលជម្លៀសពីសេរីសោភ័ណម៉ោ ចូលដល់ភូមិបានប៉ុន្មានថ្ងៃបាន?

បណ្ឌិតៈ ដេកបានមួយយប់ ។

ដារ៉ា : បានម៉ាយប់ទេ?

បណ្ឌិតៈ បានម៉ាយប់បានគេជម្លៀសទៅនៅអីកូនភ្នំដំរី ទៅនៅអីណោះបាន៧ថ្ងៃបានគេឲ្យម៉ោនៅភូមិវិញ ប៉ុនអត់បានម៉ោទេទៅនៅភ្នំស្រះម៉ារដូវភ្ជួរ ម៉ារដូវភ្ជួររួចទៅ ខ្ញុំទៅនៅតាមវាលតាមអីទៅបានប្រពន្ធកូនដែរនែ ម៉ោពីស្រះម៉ោនៅភូមិកណ្តាលនេះ ភូមិកណ្តាលពីដើមមុិញបានជាគេធ្វើបាបជាងគេ មិនត្រូវបានជម្លៀសខ្លាំងទេព្រោះគេថាភូមិនេះជាភូមិវណ្ណៈ សំបូរអ្នកមានសំបូរអ្នកចេះដឹងច្រើន ។

ដារ៉ា : អញ្ចឹងភូមិកណ្តាលហ្នឹងអ្ហេះ?

បណ្ឌិតៈ បាទ! រើអស់ខ្ទេច រំលាយចោលអត់មានសល់ ព្រោះពីដើមមុិញគ្រូបង្រៀន សុទ្ធតែកូនឪពុកម្តាយអ្នកមាន សក្តិ៣ សក្តិប៉ូលីស កុំសៀប៉ូលីសអីនៅពេញ សាស្ត្រាចារ្យអីមាននៅនេះ ហើយគេថាភូមិនេះភូមិវណ្ណៈហើយ ព្រោះផ្ទះធំៗជាប់ច្រើន អើថាវាកើតបានធំដលពេលវាកាន់ក្តាប់វារំលាយចោលអស់ វាកាត់ត្រឹមផ្ទះខ្ញុំនោះវាថាភូមិកញ្ជះគេ ។

ដារ៉ា : ហើយម៉េចបានពូអាចគេចផុតពីការស្លាប់ហ្នឹងបាន?

បណ្ឌិតៈ ខ្ញុំវាជារឿងមួយខ្ញុំមិនដែលជាប់និន្នាការ ទី១អត់មាននិន្នាការជាទាហាន ហើយជាវណ្ណៈធំៗស្អីៗ ខ្ញុំដាក់វណ្ណៈខ្ញុំជាវណ្ណៈកសិករ កម្មករ ខ្ញុំរត់ទៅនៅស្វាយមែន ក៏ប៉ុន្តែខ្ញុំរត់ទៅនៅក្រោម ទៅតាមបងប្អូនខ្ញុំនៅឧត្តរមានជ័យទៅធ្វើការរកស៊ីទៅខ្ញុំយកប្រពន្ធកូនខ្ញុំទុកនោះទៅប៉ុន្តែវណ្ណៈខ្ញុំដាក់តែកសិករកម្មុរ ប៉ុន្តែមានដែរមានប្រវត្តិគេតាមសម្លាប់ដែរណា តែដូចថាវាចៃដន្យចេះគេចផុត ហើយខ្ញុំមានតួនាទីជាប្រធានក្រុម ដូចថាយើងជាមូលដ្ឋានចេះ

ដាក់ម៉ោ ឲ្យធ្វើប្រធានក្រុម ឲ្យធ្វើប្រធានកង ហើយក្តាប់ម៉ាសារទៀត ប្រធានក្តាប់មុខសញ្ញាទៅក្តាប់ លើកទំនប់ ។ ប្រធានក្រុមខាងចម្ការ ខាងភ្ជួរខ្ញុំ ប្រធានក្រុមខាងភ្ជួរ កាលហ្នឹងបងប្អូនខាងភ្នំពេញអត់ទាន់ម៉ោទេ ។

ដាវ៉ា : អត់ទាន់ម៉ោទេណោះ?

បណ្ឌិតៈ អត់ទាន់ម៉ោទេ ។

ដាវ៉ា : អញ្ចឹងការសម្លាប់ទាំងអម្បាលម៉ានដែលអ៊ំរៀបរាប់ហ្នឹងគឺសុទ្ធតែនៅក្នុងមូលដ្ឋាន ដែលជាប់និន្នាការ?

បណ្ឌិតៈ និន្នាការកាលពីសង្គមចាស់ ជាសេរ៉ីអា ស្រេចតែគេថា ជាប់ជាទាហាន ។ ដល់ក្រោយម៉ោទៀតវាជាប់ចូលពួកនិរតី អាហ្នឹងបានវាអស់ច្រើនខាងពួកនិរតីគេម៉ោក្តាប់ ។

ដាវ៉ា : អញ្ចឹងពេលដែលពូម៉ោពីភ្នំស្រេះចូលម៉ោភូមិកណ្តាលនេះ ក្នុងរយៈពេលប៉ុន្មានខែប៉ុន្មានឆ្នាំទៅបានៗត្រឡប់ម៉ោវិញ?

បណ្ឌិតៈ ខ្ញុំនៅនោះវាចូល៣-៨ខែរហូតដល់ម៉ាភ្ជួររួច មិនមែនភ្ជួរដូចយើងសព្វថ្ងៃទេ ទាល់តែស្ទូងរួចអស់ ប្រពន្ធកូនម៉ោមុនហើយ ព្រោះយើងមុខសញ្ញានៅតាមយើងរហូតទៅ ប៉ុន្តែប្រពន្ធកូនគេឲ្យធ្វើរោងធ្វើអីនៅណោះ ផ្ទះខ្ញុំនៅណោះកន្លែងសាលារៀនកាច់ជ្រុង ។

ដាវ៉ា : អញ្ចឹងពេលហើយពីស្រែហ្នឹងពូត្រឡប់ម៉ោ?

បណ្ឌិតៈ បាទ! ត្រឡប់ម៉ោ ។

ដាវ៉ា : ត្រឡប់ម៉ោភូមិកណ្តាលនេះ?

បណ្ឌិតៈ បាទភូមិកណ្តាល ។

ដាវ៉ា : អញ្ចឹងម៉ោដល់ភូមិកណ្តាល?

បណ្ឌិតៈ ម៉ោភូមិកណ្តាលឲ្យទៅចម្ការ កាប់ព្រៃអាកន្លែងពោះ២នេះ កន្លែងកងពលសព្វថ្ងៃ ក្រៅពីហ្នឹងសុទ្ធព្រៃ ពីដើមមិញសុទ្ធតែព្រៃពីនេះទៅរហូតហ្នឹង ព្រៃអត់មានស្រឡះអញ្ចឹងទេណាចេញទៅភូមិខ្ញុំនេះទៅជើងភ្នំព្រៃ សុទ្ធតែព្រៃអុសព្រៃអីទេ ។

ដាវ៉ា : ព្រៃដើមឈើធំៗម៉ង?

បណ្ឌិតៈ បាទ! ដើមឈើធំប៉ុនៗណោះ ឆ្លងតែទំនប់ ឆ្លងតែថ្នល់ជាតិទៅអុសដឹកបាត់ បើខ្ញុំនៅពីដើមមិញខ្ញុំទៅកាប់អុសដឹកបាត់ ប៉ុនតាឆ្ងាយ ប៉ុនខ្ញុំនៅពីដើមមិញខ្ញុំទៅកាប់អុសខ្ញុំនៅតូចៗបរទេះទៅ ទៅថ្ងៃត្រង់ម៉ោវិញ នេះជើងភ្នំនេះណាជើងភ្នំព្រះនេត្រព្រះ ខ្ញុំថាដីវារួញខ្ញុំបេះតែឆ្លល់ខ្លួនខ្ញុំ ។

ដារ៉ា ៖ ដល់ពេលឥឡូវ?

បណ្ឌិតៈ ដល់ពេលឥឡូវដើរមិនបាន ។ ប៉ុន្តែឥឡូវដើរអើតឃើញមិនបានផង ។

ដារ៉ា ៖ អញ្ចឹងវិញណោះ?

បណ្ឌិតៈ អញ្ចឹងបានខ្ញុំថាពីដើមមិញអុសអីខ្ញុំកាប់តែនៅនេះទេ មិនបាកទេអាកូនឈើអីប៉ុនៗនេះអី កាប់នៅតែដើងភ្នំនេះ មិនបានមួយរយម៉ែត្រផង ។

ដារ៉ា ៖ ហើយអំពេលដែលធ្វើចម្ការហ្នឹងដាំអីខ្លះទៅ?

បណ្ឌិត ៖ ដំឡូងមី កាប់ដាំតែដំឡូងមីទាំងអស់ កាប់មុនដំបូងភ្នំស្តុកណោះ កាលនោះវាមានខ្មោចច្រើនណាស់ណា តែដីងគេយកម៉ោពីណាវ៉ៃចោលដីងទេ អត់មានកប់ទេឃើញតែឆ្អឹងឃើញតែអី ចុះវា៥-៦ខែហើយ ខ្មោចវានៅតែខោអាវ ។

ដារ៉ា ៖ ចុះពេលដែលទៅធ្វើឆ្អឹងដែរ?

បណ្ឌិតៈ ឃើញមានឆ្អឹងមាន សុទ្ធតែគេវ៉ៃពួកពាយ័ព្យ ។

ដារ៉ា ៖ ពួកពាយ័ព្យពូអ្ហេះ?

បណ្ឌិត ៖ បាទ! ពួកពាយ័ព្យ ។

ដារ៉ា ៖ វ៉ៃហ្នឹងៗពួកខ្មែរក្រហមហ្នឹងម៉ងឬក៏មុនរបបហ្នឹង?

បណ្ឌិតៈ បាទ! គេវ៉ៃ អាហ្នឹងគេវ៉ៃពួកអ្នកជាប់និន្នាការកាលពីសង្គមចាស់ ពួកទាហាន ហើយនៅនេះឲ្យតែជាប់តែមេឃុំវ៉ៃទាំងគ្រួសារ ។ ដូចតាមួយឈ្មោះ គុប យាមៗ វ៉ៃទាំងគ្រួសារកូនកម្លោះកូនក្រមុំអីទាំងអស់ កូននោះវ៉ៃ ប៉ុន្តែខ្ញុំអត់បានឃើញទេខ្ញុំនៅតែអីវាលខ្ញុំឮតែគេថាទេខ្ញុំអត់បានម៉ោទាន់ តែអាបងមួយកូនកម្លោះមួយនៅស្រែនៅវាលយើងនេះយកទៅបាត់ដែរ ។

ដារ៉ា ៖ បើគិតទៅគ្រាន់តែបែកភ្លាមមានការសម្លាប់?

បណ្ឌិតៈ សម្លាប់ភ្លាមព្រោះវាកាត់ នៅនេះបែកភ្លាមស្លាប់ភ្លាម ស្លាប់បងជីដូនមួយខ្ញុំមួយមុនគេ ២នាក់និងកូនពីរគ្រួសារ ។

ដារ៉ា ៖ ហ្នឹងនៅពេលដែលបែកភ្លាមចឹងអ្នកណាគេម៉ោគ្រប់គ្រងនៅភូមិហ្នឹង?

បណ្ឌិតៈ ភូមិ គ្រាន់តែតាមដានទៅងាប់អស់ហើយអត់មាននៅទេ ។

ដារ៉ា ៖ អ្នកភូមិហ្នឹងដែរ?

បណ្ឌិតៈ អត់ទេ មួយនៅស្ទឹងកំបុត ឈ្មោះ សន ងាប់ហើយ ពួកនីរតីម៉ោវ៉ៃគ្នា ។

ដារ៉ា ៖ គាត់ជាប្រធានភូមិនៅហ្នឹង?

បណ្ឌិតៈ គណៈឃុំ ។

ដារ៉ា ៖ គណៈឃុំឈ្មោះ សន?

បណ្ឌិតៈ ឈ្មោះ សន គណៈឃុំ ។ ដល់ក្រោយម៉ោពុថាពួកហ្នឹងវ៉ៃចោល ហើយប្រធានឈ្លបឈ្មោះ គឿន នោះក៏គេចាប់សម្លាប់ចោលដែរ ។ ហើយគណៈឃុំមុនៗវ៉ៃអស់ គណៈស្រុកគណៈ អីមុនៗវ៉ៃចោលអស់ ។ ឃើញតាមផ តាវ៉ាល់អី ឃើញក្រោយម៉ោខ្ញុំដឹងពួកនីរតីប្រែ អាប្រវត្តិផ្ទៃក្នុងនៅពេញហ្នឹងទាំងអស់ ។ ខ្ញុំវាមែនថាចេះដឹងអីទេប៉ុន្តែថាស្ដាប់ដាន ពីសម័យ ៣ឆ្នាំស្ដាប់តាមដាន ខ្ញុំឃើញគេដាក់វ៉ាដ្យូផ្សាយចឹងទៅ មុនដំបូងឃើញ ហ៊ូ នឹម និយាយ ប្រធានរដ្ឋមន្ត្រីឃោសនាការ គាត់និយាយបានម៉ាប្រាវទៅស្រាប់បាត់ បាត់ ហ៊ូ នឹម តាមដាន លែងពុឈ្មោះ ដល់ពុគេខ្សឹបខ្សៀវគ្នាថា ហ៊ូ នឹម ជាប់គុកហើយគេសម្លាប់គាត់ និយាយរាដ្យូមុនដំបូងខ្ញុំដើរធ្វើការឃើញគេនិយាយចេញពីផ្ទះគណៈឃុំ ក្រោយៗឃើញ ផ្សាយ តាប៉ែន នុត ប៉ែន នុត ក៏និយាយដែរ តាប៉ែន នុត ហ៊ូ នឹម សហរដ្ឋមន្ត្រីក្រសួង ឃោសនាការផ្សាយពីរឿងបែបប្រើប្រាស់ ស្រាប់តែប៉ុន្មានថ្ងៃអត់ពុផ្សាយទេ ។

ដារ៉ា ៖ ពុអីវិញ?

បណ្ឌិតៈ ពុតែក្មេងធម្មតាទៅ ហើយពុឪពុកខ្ញុំនិយាយ ឪពុកក្មេកខ្ញុំទេ គាត់ធ្វើការរើផ្ទះនៅស្វាយ គាត់ឃើញប្រាក់ គាត់និយាយទេណា គាត់ឃើញប្រាក់នេះប្រាក់ ខ្មែរក្រហមបោះចាយ ដល់ពេលមើលបានតិចស្រាប់តែឯកសារស្រាវរិញអស់ បិទអស់ឈប់ឲ្យមានវិញ ខ្ញុំចេះ តេតាមដាម នោះវារុះរើតែម្ដងវាថាឲ្យស្មើគ្នា កុំឲ្យមានប្រាក់វាបិទភ្លាមមិនឲ្យមានប្រាក់ បើមានប្រាក់វាមានពុរលួយការផរជាតិ ។ ហើយខ្ញុំមិនដឹងវាអាម៉េចខ្ញុំវា ហេតុតែខ្ញុំនៅ នេះមានបងជីដូនមួយមួយ ដូចថាគាត់ធ្វើខ្មែរក្រហមដែរណា មេខ្មែរក្រហមដែរព្រោះគាត់ ជាសាស្ត្រាចារ្យគាត់នៅនោះដែរ ឈ្មោះ ឈួន ។

ដារ៉ា ៖ គាត់នៅរស់ឬក៏ស្លាប់?

បណ្ឌិតៈ គាត់ស្លាប់ដែរ ពួកនោះចាប់ដូចគ្នា គាត់បាញ់ខ្លួនគាត់ ។ គាត់ឈ្មោះ ឈួន នោះពីដើម ឡើយគាត់ជាខ្មែរក្រហមដែរ កាលនោះសម្ដេចសីហនុជាអ្នកបង្កើតតើ អរ! ខៀវ សំផនៗ កាលគាត់នេះគាត់ទៅរៀនឌីប្លូមនៅបាត់ដំបងគេចុះផ្សាយចាប់គាត់ ពួកយើងខាង ក្នុងដេញចាប់គាត់សម័យ គាត់រត់នោះ ។

ដារ៉ា ៖ អរ! កាលលន់ នល់អ្ហោះ?

បណ្ដេតៈ ទេមុនលន់ នល់ទៀត សម័យសម្ដេច កាលនោះរត់ទៅនៅអីណាទេ អរ! ទៅនៅប៉ៃលិន គាត់ទៅនៅកប់ខ្លួននៅប៉ៃលិន កាលនោះលោក ខៀវ សំផន គាត់ធ្វើរដ្ឋមន្ត្រីក្រសួងអប់រំ ។ ដល់គាត់បានធ្វើរដ្ឋមន្ត្រីក្រសួងអប់រំ គេស្រាវជ្រាវរកសមាជិកចាស់របស់គេអ្ហាស ឧទាហរណ៍ថា បើប្រៀប ដូចថាសមាជិកបក្សជនចុះ កាលសម័យអាពតគេថាបក្សជនធំ បក្សជនឆ្នាំនេះ អ្នកឯងចូលបក្សជនពីឆ្នាំ៥០ប៉ុន្មាន ៤០ប៉ុន្មាន កាលពីសម័យសង្គ្រាមនោះ ទាហានហ្នឹង បានគេទៅតាមដាក់បណ្ដាញមួយទៅតាមគាត់យកម៉ោប្រឡងបាក់អង ដល់ប្រឡងបាក់អង ជាប់ បាក់ឌុបជាប់ ចេញធ្វើសាសាក៏ជាប់ទៀត រដ្ឋមន្ត្រីក្រសួង កូនចៅ ដល់នេះគាត់ធ្វើការ ជាមួយ ខៀវ សំផន រហូតដល់ថ្ងៃគាត់ធ្វើគ្រូបង្ហាត់នៅ សៀមរាបបានម៉ាឆ្នាំ សម័យលន់ នល់ ទៅកំពង់ចាមគាត់ចូលធ្វើក្លែអងជាមួយកូនចៅ ក្រោមបញ្ជាគាត់ ក្រោយម៉ោទៀតសម្លាប់ដូចគ្នា ។

ដារ៉ា : ពេលបានចូលធ្វើតស៊ូជាមួយខ្មែរក្រហមនៅកំពង់ចាមហ្នឹង ពេលបានជ័យជម្នះថ្ងៃ១៧ មេសាគាត់ម៉ោហ្នឹងអ្ហេះ?

បណ្ដេតៈ ម៉ោៗគាត់បានឃើញគេសម្លាប់មនុស្សចំពោះបងប្អូននៅនេះ គាត់ហាមពួកមេឃុំខាង ពាយ័ព្យហ្នឹងថា ប៉ិនហ្នឹងបានហើយ យើងសម្លាប់ៗមនុស្សណាដែលខ្លាំង ចំពោះខាងនេះ យើងកំតរាលដល់គំនុំបុគ្គល រហូតដល់ភូមិកណ្ដាលនេះដូចថាវាមានៗនេះទៅ ប្រជាជនកុំអី ខ្ទេច ព្រោះគេស្អប់ភូមិកណ្ដាលនេះព្រោះគេថាភូមិវណ្ណៈមានច្រើនៗ អ្នកចេះដឹងក៏ច្រើន ដែរអត់មានសល់ទេ នេះផ្ទះនេះ ខាងគ្រួសារនេះដីធំម្ចាស់អត់នៅទេ កូនគាត់កុងសៀ ភ្នំពេញ ពីដើមម៉ិញសក្ដិពខ្ញុំថាធំប្រហែល ស ខេង ក្រុម ស ខេង ខ្ញុំថាអញ្ចឹង អ៊ឹម៉ាណារិន គាត់សក្ដិ ពភ្នំពេញ ។ ហើយនៅនេះគាត់ ម៉ោនេះគាត់កុម្ម៉ង់ដង់អាប៉ាទីយ៉ង់ ឈ្មោះគាត់ ពិន ឆាយណារិន ។

ដារ៉ា : ពិន ឆាយណារិន?

បណ្ដេតៈ សក្ដិ៥ គាត់នៅមេកុម្ម៉ង់ដង់ គាត់មៅជាប់សាច់សន្ដានអីរាបដូចស្បែកគោចឹង ។

ដារ៉ា : ចឹងពូដែលទៅធ្វើចម្ការដាំដំឡូងមីដំឡូងអីហ្នឹង អាហ្នឹងនៅក្នុងឆ្នាំណា?

បណ្ដេតៈ ឆ្នាំ១៩៧៥ចូល៧៦ ។ ឆ្នាំ៧៥ យើងមិនរំដោះបាន វាក្ដាប់បានទូទាំងប្រទេស ៦-៧ខែ ចប់រដូវវស្សានេះចប់ធ្វើស្រូវយើងត្រូវអូសកម្លាំងទៅកាប់ព្រៃភ្នំ នៅកន្លែងកងពលនៅសុត តែព្រៃ ។

ដារ៉ា : អាហ្នឹងគេហៅព្រៃអី?

បណ្ឌិតៈ ព្រៃពោះពីរ?

ដារ៉ា ៖ ព្រៃពោះពីរ?

បណ្ឌិតៈ ចល័តនៅនោះ ប៉ុន្តែចល័តអត់ឆ្ងាយ ចល័តក្មេងៗ ប៊ិនៗ នេះនៅជិតខ្ញុំ ខ្ញុំទៅកាប់ហើយខ្ញុំភ្ជួរ ខ្ញុំប្រជាជនមូលដ្ឋាន និយាយឲ្យត្រង់វាធូរបន្តិច ធូរត្រង់ថាខុសត្រូវបន្តិចបន្តួចគេមិនសូវប្រកាន់ ដូនកាលគេឲ្យយើងតួនាទីសម្រាប់ ប្រធានក្រុម ដូចជាប្រធានកង ដូចថាគេចល័តមុនៗ ទៅ ដូចថាប្រធានក្តាប់រួមអីចឹងទៅ ក្តាប់ម៉ាមុខសញ្ញាភ្ជួរស្រែភ្ជួរចម្ការ ដូនកាលក្តាប់គ្នា៣-៤នាក់ទទួលមួយក្រុម ។

ដារ៉ា ៖ កាលហ្នឹងធ្វើជាចម្ការទេណោះ?

បណ្ឌិតៈ បាទ! ធ្វើជាចម្ការ ។

ដារ៉ា ៖ ហើយដល់ឆ្នាំ៧៦ហ្នឹងអ្នកណាធ្វើភូមិ ធ្វើឃុំអីទេ?

បណ្ឌិតៈ ដល់មេភូមិសព្វថ្ងៃគាត់ទៅអាមេរិក ។

ដារ៉ា ៖ ឈ្មោះអីទៅ?

បណ្ឌិតៈ ឈ្មោះ ឈាវ ។

ដារ៉ា ៖ ឈ្មោះ ឈាវ?

បណ្ឌិតៈ ឈាវ បាទ ឈ្មោះ ឈាវ នោះបងប៊ិ ឈួន ដែលខ្ញុំនិយាយនោះ ។

ដារ៉ា ៖ ហើយចុះមេឃុំកាលហ្នុង?

បណ្ឌិតៈ មេឃុំខ្ញុំ ដូចគណៈឃុំគេមានដាក់ ដូចថាអាប៊ិសនដែលគេវ៉ៃនោះ តាសនហ្នឹងមួយ បើខ្ញុំចាំមានពីរ កាលហ្នុងឃុំអត់មានធ្វើនៅនេះទេនៅអីចុងណោះ អានេះអត់ទាន់បែកជាឃុំទេគ្រាន់តែគេដាក់ថានេះឃុំព្រះនេត្រព្រះ ។ ដែលខ្ញុំដឹងជាងគេខ្ញុំស្គាល់តែអាប៊ិ សន បន្ទាប់ម៉ោអ្នកម៉ោពីកើតៗ ។

ដារ៉ា ៖ ចុះដល់ឆ្នាំ៧៦ហ្នឹងមានអ្នកម៉ោពីភ្នំពេញនៅ?

បណ្ឌិតៈ មានហើយ ដើមឆ្នាំ៧៦អ្នកភ្នំពេញជម្លៀសម៉ោៗតាមភូមិ ។

ដារ៉ា ៖ ម៉ោនៅតាមភូមិហ្នឹងអ្ហេះ?

បណ្ឌិតៈ បាទ!

ដារ៉ា ៖ ហើយស្ថានភាពអ្នកជម្លៀសម៉ោពីភ្នំពេញយ៉ាងម៉េចទៅពូ?

បណ្ឌិតៈ អ្នកម៉ោពីភ្នំពេញ.....(ឮសម្លេងកុងស្តាប់មិនបាន)

ដារ៉ា ៖ សាលារៀនឈ្មោះអីហ្នឹង?

បណ្ឌិតៈ សាលារៀនព្រះនេត្រព្រះនេះ ។

ដារ៉ា ៖ សាលាបឋមសិក្សាហ្នឹង?

បណ្ឌិតៈ បាទ! សាលាបឋមសិក្សា ដល់ពេលដាក់ទៅភូមិនេះ គេយក ជួនកាលកាត់ប៉ុន្មានគ្រួសារទៅភូមិនេះអីចឹងទៅយើងកាត់ឲ្យគេទៅ ប៉ុន្មានគ្រួសារមានមេគេមួយផ្ទះគេយកទៅប៉ោយព្រីង ទៅប៉ោយសំរ៉ោងគេឲ្យដាក់តាមភូមិប៉ុន្មានគ្រួសារៗចឹងទៅ ហើយភូមិខ្ញុំនេះនៅប៉ុន្មានគ្រួសារនៅសាលារៀន ។

ដារ៉ា ៖ អញ្ចឹងពូអ្នកកត់ឈ្មោះដែរ?

បណ្ឌិតៈ បាទ! ខ្ញុំជាអ្នកកត់ឈ្មោះ ។

ដារ៉ា ៖ ប្រហេលជា តាមការប៉ាន់ស្មានរបស់លោកពូប្រហែលជាប៉ុន្មានគ្រួសារដែលម៉ោកាលហ្នុង?

បណ្ឌិតៈ ទេខ្ញុំដូចជាចាំមិនបាន ដូចថាធ្វើៗមិនបានយកចិត្តទុកដាក់ មិនបានចាំណា ធ្វើៗដូចថាបំពេញ ខ្ញុំដឹងតែភូមិខ្ញុំច្រើន ចូលជិតមួយរយគ្រួសារភូមិនេះ ។

ដារ៉ា ៖ អ្នកម៉ោពីភ្នំពេញ?

បណ្ឌិតៈ បាទ! ម៉ោពីភ្នំពេញ មានអ្នកអរិយក្សត្រ អ្នកព្រៃវែង អ្នកតាកែវ ម៉ោចំរុះគ្នា ។ ផ្ទះនេះនៅផ្ទះនេះអាពតមិនបានរើទេ នៅ៣,៤,៥គ្រួសារ គេម៉ោដែរៗម៉ោពីម្សិលម៉ិញ ប៉ុន្មានថ្ងៃមុនម៉ោអ្នកអរិយក្សត្រម៉ោរកម៉ោខ្ញុំ ថ្ងៃមុនម៉ោទៀតម៉ោអ្នកអូស្រ្តាលី ។ បើខ្ញុំនៅនេះបើនិយាយទៅខ្ញុំជាអ្នកមូលដ្ឋានចាស់ ខ្ញុំមិនដែលប្រកាន់ទេ ខ្ញុំមិនដែលបានថាអ្នកឯងធ្វើអីទេ ខ្ញុំមិនទៅរករឿងអីទេ អ្នកឯងធ្វើអីបានស៊ីធ្វើទៅ អ្នកថ្មីលួចបានស៊ីៗទៅ ថីបើខ្ញុំអ្នកមូលដ្ឋាន ដូចថាបើថាគេប្រើអីទៅខ្ញុំទៅៗ ធ្វើម៉េចបើអ្នកឯងលួចស៊ីក៏លួចទៅ អ្នកឯងលួចបានស៊ី ខ្ញុំថាបើអ្នកជើងខ្លាំងមិនរស់ បានខ្ញុំនិយាយថាចំពោះអ្នកនេះថាបើរកអាអ្នកនៅ ក្តាប់ជើងចាស់ធ្វើបាបហ្នឹងងាប់អស់ ជួនកាលម៉ោឈឺងាប់ ជួនកាលទៅវាមានពាររវេរទៅ បានខ្ញុំថាអ្នកពារវាដាក់ បានខ្ញុំថាយកអាពាក្យពារមកដាក់ ។ ងាប់អស់អាជើងខ្លាំងក្នុងភូមិនេះ២-៣នាក់ សុតតែវាមិនយកអាចិត្តពិចារណាដឹងខ្លួនអួស ឲ្យធ្វើចេះតែធ្វើ អាមនុស្សមិនសមរើចេះតែទាត់ធាក់ អាកូនក្មេងប៉ុនណេះចេះតែរើទាត់ធាក់ដែលទៅលួចអាដំឡូងស៊ី ខ្ញុំអត់ឃើញមានរស់ណាងាប់អស់អាលីងតាមខ្ញុំចំនាំពួកដែលធ្វើបាបគេ ។

ដារ៉ា ៖ ចុះអ្នកដែលម៉ោពីភ្នំពេញដែលជាន់មួយរយគ្រួសានៅក្នុងភូមិអីហ្នឹង ភូមិពូហ្នឹងកាលចុង ក្រោយម៉ោមាននៅ?

បណ្ឌិតៈ ចុងក្រោយងាប់ច្រើនណាស់ ចុងក្រោយខ្លាំងពេលនិរតីកាន់ក្តាប់ សម័យនោះខ្ញុំក្តាប់ឃើញ យាយ ថែម គាត់ ខ្ញុំស្គាល់ច្បាស់ណាស់យាយថែមគណៈស្រុកនេះខ្ញុំស្គាល់ច្បាស់គណៈ ស្រុកនេះ យាយថែមគាត់តែងតែម៉ោធ្វើការ ដែលពួកនិរតីម៉ោពីចុងឆ្នាំ១៩៧៦ ឆ្នាំនោះ ខ្ញុំអាចក្តាប់បានថា ហេតុផលមានតែវៃវៀតណាម ខ្មែរក្រហមវៃវៀតណាមចូលប្រាវ ដល់វៀតណាមវៃរុញម៉ោវិញ ដល់ពួកយួនរុញម៉ោវិញរុញម៉ោដល់មាត់ទន្លេហើយ ហើយវាជកពួកអ្នកចល័ត ដូចក្មេងៗប៉ុននេះអីវាជកម៉ោក្តាប់ ហ្នឹងពួកដូចថា បើតាមគេ និយាយ តាមដឹងមើលអាសៀវប្រវត្តិសាស្ត្រហ្នឹងដូចខ្ញុំមើលឃើញថាពួកនេះក៏ខ្មែរ ដល់យើង ពួកហ្នឹងវៃវៀតណាមដល់វៀតណាមវៃដេញវិញបានវៃខេត្តបាត់ ខាងកើតទន្លេ មេគង្គ ជម្លៀសពួកចល័តទាំងអស់ដែលនៅណោះៗយកម៉ោនៅណេះវិញ ម៉ោដល់ដំបូង អត់ដឹងអីទេ ខ្លះនិយាយ ដូចថាខ្លះមិនដែលស្គាល់ស្រូវ ដូចថាពួកធ្វើការដែរ ប៉ុនខ្លះនៅតែ ភ្នំពេញធ្វើតែស្រែអំបិលធ្វើអី នៅចល័ត ពួកស្រែអំបិលឡើងដើមឈើឡើងដូចយើង មនុស្សចឹងៗ

ដារ៉ា ៖ ស្រីៗ?

បណ្ឌិតៈ បាទ!

ដារ៉ា ៖ ចឹងពូដឹងថាមានសង្គ្រាមជាមួយវៀតណាមតាមរយៈអីដែរកាលហ្នុង កាលជំនាន់ហ្នុង?

បណ្ឌិតៈ ហ៊ឺ! ខ្ញុំដូចជាពូ នេះឯកសារនេះសៀវភៅ ប៉ុនខ្ញុំមិននេះបានទេ ប៉ុនតែពូវៃវៀតណាមៗ ហើយដល់ពេលពួកនិរតីម៉ោ ឃើញតែកប៉ាល់ហោះ ដូចថាវាម៉ោចេះឃើញកប៉ាល់ហោះ ទៅវាថា រត់ក្រាបទៅណារត់ក្រាប ដល់ក្រោយម៉ោបានពូថាវៃជាមួយវៀតណាម បានពួកម៉ោនេះពួកចល័តទេ ខ្ញុំចេះតែយល់ថា ខ្ញុំតាមដានសភាពការណ៍ស្តាប់មើលថាពួក ចល័តដែលគេចាប់កៀរម៉ោណេះ ម៉ោក្តាប់ពួកណេះ មិនមែនម៉ោក្តាប់ទេមុនដំបូងម៉ោហ្នឹង ម៉ោជា

ដារ៉ា ៖ ជាអ្នករស់នៅ?

បណ្ឌិតៈ ជាអ្នករស់នៅ បើតាមធ្វើការប្រាប់ ដល់នេះគេហៅប្រជុំៗ ពួកយាយ ថែម ធ្វើរដ្ឋ ប្រហារ មានរដ្ឋប្រហារ ខ្ញុំមិនចាំថ្ងៃទេ មួយថាកាំភ្លើងទៅដាក់នឹង គ្រាប់កាំភ្លើងធំប្រុង បាញ់ដាក់ផ្ទះប៉ុល ពត ប្រុងរដ្ឋប្រហារហើយមានកាំភ្លើងធំ ដល់ពួកអគ្គការដឹងទាន់បាន

អង្គការនោះមែនពួកខាងតាម៉ុកទេ ខាងភូមិភាគនោះពួកខាងនីរតីគេអាចវ៉ៃប្រានយើង បើតាមការពិតយួនដកដោយសន្តិវិធីទេ រំលោភច្បាប់អង្គការសហប្រជាតិទេម៉ោវ៉ៃនេះ អានេះខ្ញុំមើលសភាពការណ៍ក្រោយវាត្រូវ យួនដកទៅពួកវាថាឲ្យ មុនដំបូងពួកខាងឧត្តរនេះវ៉ៃអត់ចេញទេ វ៉ៃម៉ោចេះតែរួមរស់បាន ដល់វ៉ៃក្រោយម៉ោទៀតវាដាក់ពួកខាងនីរតីពួកតាម៉ុកអី ថាវ៉ៃប្រានយួនបាន តែតាមការពិតយួនដកដោយខុសច្បាប់អន្តរជាតិ ដែលតាមខ្ញុំមើលតាមដានសភាពការណ៍ហ្នឹងម៉ោណា ហើយដល់ពេល បានម៉ោដល់នេះទៅ គេថាពួកឧត្តរក្បត់ កាលណោះមានទំនាក់ទំនងគ្នាហើយ ព្រោះខ្ញុំ វាមានអាប៉ិដាលមានខាងយោធារត់ម៉ោហើយ ពួកខាងតំបន់ខាងណោះពួកខាង រស់ ញឹម រស់ ញឹម គាត់ភូមិភាគ ។ ម៉ោដល់ម៉ោតាមយកអាសំបុត្រមួយដែលមានឯកសារ កូននីរតសាគេពីរនាក់រត់គេចម៉ោនេះបានគេប្រាប់ថារឿងត្រូវ នេះនោះ ពួកនោះក្បត់ៗ ដល់ក្បត់ពួកនេះបោសសំអាតតែដូរកម្មាភិបាល ដូរកម្មាភិបាលក្បត់ណា ឯកសារនេះខ្ញុំស្តាប់លោកតាជាស៊ីម ម៉ោប្រជុំនៅមន្ទីរបក្សនៅស្វាយស៊ីសុផុន គាត់និយាយដែរ ។

ដារ៉ា : ពីឆ្នាំណា?

បណ្ឌិតៈ ២-៣ឆ្នាំមុន ៥-៦ឆ្នាំមុនគាត់សម្ភោធមន្ទីរបក្សគាត់លើកនៅសម័យគាត់នៅហ្នុង គាត់លើកថានៅសម័យនោះដល់ពេលគាត់ ព្រោះគេបោសសំអាតដល់ចូលប្រជាជន គាត់ថានៅមិនបានទេ សម្លាប់មនុស្សច្រើន សម្លាប់ប្រជាជន បោសសម្លាប់ដល់ប្រជាជន បានខ្ញុំថាវាដល់អាខ្វះគ្នាធ្វើទាហានតាំងពីអាសម័យឥស្សរៈម៉ោនោះ ជាប់និន្នាការថាយកទៅសម្លាប់ចោលអស់ អាខ្វះគ្រាន់តែធ្វើទាហានដូចថាកុម្ម៉ង់ដូរឈ្នួលដូរយកស្រូវកយក៏យកទៅសម្លាប់ចោលដែរឲ្យតែជាប់និន្នាការជាទាហាន និងមេកង មេកង មេក្រុមពីសម័យយើង ៧៥ម៉ោ ពួកខាងពាយ័ព្យក៏វាយកទៅសម្លាប់ចោលដែរ អាហ្នឹងជាប់កំអែលពួកពាយ័ព្យក្បត់សម្លាប់ចោលអស់ បានភូមិខ្ញុំនេះរត់ច្រើន ពេលនោះហើយពួកភូមិកណ្តាលរត់ចង់អស់មនុស្សប្រុស ខ្ញុំសឹងតែមិនបាននៅនឹងគេដែររវេចសំពាយរត់ហើយ ដល់រៀបថារត់ហ្នឹងមើលទៅពួកនៅចុងភៅប្រាប់ថា ម៉ាយប់សិនអានេះឮថាវាឈប់ហើយ ថាឈប់ហើយឈប់វ៉ៃហើយ ចាំមើលម៉ាយប់ចុះ ដល់បានព្រឹកឡើងគេម៉ោធ្វើសន្និបាត្រយោធាគេលើកលែងទោស អ្នកជាប់និន្នាការក៏ដោយក៏លើកលែងទោសឈប់សម្លាប់ហើយ គេម៉ោធ្វើនៅមុខវត្តនេះ គេជុំម៉ាឃុំព្រះនេត្រព្រះទាំងអស់គ្នា លើកលែងទោសថាឈប់លើកលែងទោសហើយបានខ្ញុំនៅជាប់ ។

ដារ៉ា ៖ កាលម៉ោធ្វើមីទ្ទិញអ្នកណាម៉ោមានចាំឈ្មោះទេ?

បណ្ឌិត៖ ខ្ញុំចាំមិនបានទេ ហ្វី! ប៉ុហ្នឹងឈ្មោះ ស ដែលធ្វើមេទ្ទីញ ឈ្មោះតាស១ ក្មេងទេកាលហ្នុងឡ តែធំហៅតាហើយ ឈ្មោះតាស ។

ដារ៉ា ៖ មានយាយ ថែម ចូលរួមទេពេលធ្វើមីទ្ទិញហ្នឹង?

បណ្ឌិត៖ អត់ទេមានតែពីរនាក់ទេម៉ោ យាយថែមគណៈស្រុក ។

ដារ៉ា ៖ អញ្ចឹងពេលដែលពួកនីរតីម៉ោហ្នឹងគឺនៅចុងឆ្នាំ៧៦ចឹងអ្ហេះ?

បណ្ឌិត៖ បាទ! ៧៦ ។

ដារ៉ា ៖ ចុះមុនហ្នឹងអ្នកណាជាគណៈស្រុកព្រះនេត្រព្រះ?

បណ្ឌិត៖ ឈ្មោះ ហឹង, មង, តាវ៉ាល់ ហើយបានតាហឹង តាវ៉ាល់ តាមង ពីរនាក់ហ្នឹង មួយខាង យោធា មួយខាងស៊ីវិល ។ ហើយមាន៣-៤នាក់ទៀតឈ្មោះ ឆាង មួយ និងខាង សេដ្ឋកិច្ចខាងអី ក្នុងរចនាសម្ព័ន្ធ៥នាក់ ។

ដារ៉ា ៖ ហើយពេលដែលពួកនីរតីម៉ោ អញ្ចឹងយាយថែមម៉ោតែម្តង?

បណ្ឌិត៖ ម៉ោបាទ ហើយបើគណៈឃុំស្រីនៅនេះកាលមុនឈ្មោះថា ឈ្មោះ នារីថា ក្រោយម៉ោឈ្មោះ ឡូញ ។

ដារ៉ា ៖ ឈ្មោះនារីថា ក្រោយម៉ោឈ្មោះ ឡូញ វិញ?

បណ្ឌិត៖ ឡូញ ។

ដារ៉ា ៖ ចឹងនារីថាហ្នឹងមែននីរតីទេចឹង?

បណ្ឌិត៖ នីរតី ។

ដារ៉ា ៖ ចឹងធៀបទៅនឹងការគ្រប់គ្រប់របស់ ហឹង ហើយនឹងមួយទៀតឈ្មោះអី?

បណ្ឌិត៖ តាហឹង តាមង តាវ៉ាល់ ។

ដារ៉ា ៖ តាហឹង តាមង តាវ៉ាល់ ហ្នឹង ហើយការគ្រប់គ្រងរបស់យាយថែមក្រោយម៉ោទៀតហ្នឹង វាខុសគ្នាម៉េចដែរ?

បណ្ឌិត៖ ខុសគ្នាត្រង់ចេះ ពួកអ្នកគ្រប់គ្រងមុនម៉ោដល់វាវៃចោលមួយសារ ដល់ពួកអ្នកវណ្ណះ ទាហាន ដែលជាប់និន្នាការទាហាន ទាហានប៉ុណាដែលធំៗម៉ាប្រាវមុនមិនច្រើនទេ ដូចថា ម៉ាភូមិខ្ញុំចេះមានអ្នកធ្វើការធំៗប៉ុន្មានគ្រួសារទេ ហើយនិងជំទប់ មេឃុំ មានតែប៉ុន ណោះឯងក្រុមពួកនោះ ម៉ាប្រាវទៅបានយើងធ្វើពលកម្ម ពលកម្មធ្វើទំនប់ ធ្វើប្រឡាយ ធ្វើទំនប់ធ្វើ ប្រឡាយ អាហ្នឹងផាប់តាមហ្នឹងច្រើនដែរ ដូចទំនប់កំបោរស្រេះ ដូចទំនប់

ស្ពានថ្ម អានេះរួចពីកំបោរស្រេះចល័តចូលទៅត្រង់ណោះទៀតហើយអត់មានបានចូលភូមិទេ ប៉ុនៗណោះប៉ុនប្អូនៗនេះមិនបានចូលភូមិទេ នៅដូចតែខ្ញុំកាលហ្នុងខ្ញុំអាយុ៣០ជាងហើយ ម៉ោបានកាន់គោ មូលដ្ឋានកាន់គោប្រើ ចល័តទៅទៀត ដល់ក្រោយម៉ោទៀតបានដល់ ពេលនោះនីរតីចូលម៉ោខ្លះហើយ ដល់ពេលរួចទំនប់ស្ពានថ្មនីរតីចាប់ចូលម៉ោហើយបានត្រូវ អាទំនប់យើងនេះត្រូវម៉េម៉ាយអាទំនប់ស្ពានថ្មហៅស្ពានម៉េម៉ាយ កាលនោះខាងពាយ័ព្យធ្វើ ដល់ពេលវាមានព្រួសប្រាស់រឿងរ៉ាវចាប់សម្លាប់គ្នាវាទៅ ស្ពាននឹងទុកចោលពួកនីរតីម៉ោវាអត់ធ្វើទេ ។ ពួកនីរតីវាអត់មានធ្វើទំនប់ធ្វើប្រឡាយទេ ម៉ោក្តាប់តែសេដ្ឋកិច្ចធ្វើស្រែ អត់មានដែលទៅធ្វើនេះធ្វើនោះទេ អត់ធ្វើអីទេ ដល់ពេលថារបបប្រែប្រួលអារៀងវា ប៉ះពាល់នេះម៉ោបានវៃអារបបខាងលេបណ្តើរៗម៉ោដល់ប្រជាជន ដល់ប្រជាជន អ្នកនិន្នាការ ដូចថាខ្ញុំធ្វើមុនប្រធានឈ្លបប្រធានកងមុនតែមិននេះវាយកទៅសម្លាប់ចោល មេភូមិកាលពីសម័យពាយ័ព្យត្រូវសម្លាប់ចោល អត់ទេមេភូមិខាងលិចៗនៅមេភូមិសម័យពួកវាម៉ោដល់ភ្លាមចប់១៧មេសាភ្លាមវាឲ្យធ្វើមេភូមិ ១៧មេសា ដល់ពេលពួកនីរតីម៉ោក្រោយបង្ហើយម៉ោចាប់ពួក ទាំងអស់ទាំងគ្រូបង្រៀនគ្រូអីខ្ទេចឲ្យតែមាន មេដប់ខ្ទងចាប់អស់ អ្នកណារត់ទាន់ៗ អាណារត់ទៅឆាប់ក៏ឆាប់ អាណាដែលគេចាប់បណ្តើរទៅកងហើយកន្លែងនេះវៃមួយដែរតើធំ ។

ដារ៉ា : ឈ្មោះអីគេកន្លែងហ្នឹង?

បណ្ឌិតៈ កន្លែងវៃហ្នឹងនៅផ្លូវចូលកន្លែងមានប៉ាយវត្តមួយនោះ ខាងណោះកន្លែងវៃ បើអានេះៗនៅខាងក្រោយផ្ទះវា ផ្ទះវានៅអញ្ចេះវៃប្រហេលមួយរយម៉ែត្រ ទាំងខ្សែៗ ពួកខ្ញុំលែងហ៊ានទៅបៀតហើយរត់យករួចតែខ្លួន រត់លែងបៀតឃើញព្រៃតែគេថា ។

ដារ៉ា : ចុះក្រោមរបបយាយថែមនោះម៉េចវិញ?

បណ្ឌិតៈ មានអីរបបយា ថែម នោះ ក្រោមនោះគេចាប់ពីកម្មាភិបាលមុន តាមមុខសញ្ញា បើថាកងទ័ពថាចាប់ផ្លូវទ័ពហើយបានកម្មាភិបាលមូលដ្ឋាន កម្មាភិបាលទៅបានដល់យើងប្រជាជន ។

ដារ៉ា : ប្រជាជននិងមានកំហុសអីទៅ?

បណ្ឌិតៈ ប្រជាជនវានៅមានការសល់ សល់ដូចជាអាយើងសល់ពីធ្វើមេភូមិចាស់ដូចខ្ញុំចឹង ដែលសល់លួចលាក់បានម៉ោដែលសល់ពួកពាយ័ព្យវាមិនបានធ្វើនោះ សល់ពីវណ្ណៈប្រវត្តិរូបម៉ោវាស្រាវយកទាំងអស់ ទាហាន មេដប់ខ្ទង មេ៥០ខ្ទង មេឃុំអីពួកពាយ័ព្យវាវៃរួចម៉ាសារ

ហើយ អាហ្នឹងពួពាយ័ព្យចូលម៉ោដល់ហើយឆ្នាំ៧៥វាវ៉ៃពួកម៉េឃុំ មេភូមិ មេឃុំ ជំទប់អីវាចាប់វ៉ៃម៉ាសារហើយ កាលនោះវ៉ៃតែប៉ុនណេះទេ និងនាយទាហានណាធំៗ ។ ដល់ពេលពួកនីរតី បានបោសសំអាតម៉ោដល់បងប្អូនយើងអ្នកស្រុកស្រែ អ្នកមានប្រវត្តិរូប ។

ដារ៉ា : លោកពូមានប្រសាសន៍មុនថាស្គាល់យាយ ថែម ច្បាស់ហ្នឹងស្គាល់យ៉ាងម៉េចទៅ?

បណ្ឌិតៈ ខ្ញុំស្គាល់គាត់ទៅម៉ោៗហ្នឹងស្រុកនេះឯង ពេលប្រជុំគេហៅខ្ញុំទៅប្រជុំហើយខ្ញុំធ្វើប្រធានក្រុមប្រជុំទៅខ្ញុំឃើញពួកនីរតីគេម៉ោ ហើយដល់ថ្ងៃរត់ខ្ញុំដឹងផែនការមុនទៀត ដឹងថាគេ ដល់មើលសភាពការណ៍វាមិនស្រួល ថ្ងៃវាចេញពីនេះទៅហ្នឹង ដល់ពេលប្រជុំរួចបានវាដឹងថាផែនការគេវ៉ៃម៉ោដល់ក្រឡាញ់ហើយ ចូលម៉ោដល់ក្រឡាញ់វាហៅពួកខ្ញុំម៉ោចេញ លែងប្រជុំផ្សេង ឲ្យទៅចុះ នៅសល់តែពួកគាត់ប៉ុន្មាន នីរតី ពួកកំពង់ឆ្នាំងអី មានពីរបក្សមួយទៀតហើយ ចូលទៅថាគេនាំខ្ញុំទៅចូលឲ្យពួកណាដែលនៅមិនគួរណា ខ្លះបានយកទាំងមេភូមិដែលត្រូវនឹងវាទៅវានាំទៅទម្លាយរហូត ភូមិកណ្ដាលមានទៅ២-៣នាក់ដែរ វានាំទៅដូចថាប្រធានកងដែលត្រូវជាមួយនឹងវាជិតជិតទៅវានាំទៅ ខ្លះរត់ម៉ោវិញទៅ ។

ដារ៉ា : ចុះយាយថែមគាត់ចុះឡើងម៉ោឃុំព្រះនេត្រព្រះហ្នឹងញឹកញាប់?

បណ្ឌិតៈ ញឹកញាប់ អាថ្ងៃប្រកាសសម្លាប់មនុស្សពីរនាក់នៅមុខហ្នឹង មុខគាត់មុខយាយថែមហ្នឹងដែលចាប់នារីខុសសីលធម៌ ។

ដារ៉ា : ឈ្មោះអីខ្លះកាលហ្នុង?

បណ្ឌិតៈ ខ្ញុំមិនហ៊ានទៅមើលផង ។

ដារ៉ា : ឈ្មោះអីខ្លះពូ?

បណ្ឌិតៈ ខ្ញុំអត់ស្គាល់ទៅឈ្មោះ មិនមែនភូមិខ្ញុំភូមិគេផ្សេងទេ ។

ដារ៉ា : កាលហ្នឹងថាធ្វើមេទ្ទិញនៅមុខវត្ត?

បណ្ឌិតៈ ហ្នឹងហើយមេទ្ទិញនេះ ចាប់វ៉ៃនេះវ៉ៃមុខវត្ត ។

ដារ៉ា : ខុសសីលធម៌ពីរនារីបុរសហ្នឹងអ្ហេះ?

បណ្ឌិតៈ នារីបុរសបាទ ។

ដារ៉ា : ហើយកាលធ្វើមីទ្ទិញយាយ ថែម ម៉ោ?

បណ្ឌិតៈ យាយថែម ។

ដារ៉ា : ចុះម៉េចអ៊ំ?

បណ្ឌិតៈ ខ្ញុំអត់ហ៊ានទៅ ។

ដារ៉ា ៖ អត់ហ៊ានទៅមើចដឹងថាពិធីហ្នឹងនៅ?

បណ្ឌិតៈ ចុះខ្ញុំឮគេនិយាយ ចុះផ្ទះខ្ញុំនៅភូមិត្រង់ណោះឯង ខ្ញុំនៅផ្ទះខ្ញុំត្រង់ណោះ ខ្ញុំថាមុខតែគេវ៉ៃមនុស្សហើយខុសសីលធម៌ព្រោះថាគេតាមដាន ដល់តែខ្ញុំតាមថាគេវ៉ៃមើចខ្លះ គេប្តេជ្ញាចេះ មិនហ៊ាននិយាយ (ស្តាប់មិនច្បាស់) ។

ដារ៉ា ៖ យាយថែមអ្នកនិយាយ?

បណ្ឌិតៈ បាទ! ដល់ហើយមួយទៀតយើងខាងពាយ័ព្យឈ្មោះ សុខ សំអាង សំអាង ហ្នឹងថាចប់ពីនេះទៅ ដល់ក្រោយមោពួកនីរត់ចាប់សម្លាប់ដែរ គណៈស្រុកដែរគណៈពាយ័ព្យដែរ ។ ហើយខ្ញុំមានបងជីដូនមួយរបស់ខ្ញុំគាត់ដូចថាគាត់ចាញ់គាត់នឹកឃើញ គាត់ដើរនិយាយពីនេះពីនោះ គាត់មោបបួលខ្ញុំចង់ធ្វើរដ្ឋប្រហារ ដូចថាចង់ធ្វើរដ្ឋប្រហារតិចទៅណា គាត់ដឹងថាខាងពាយ័ព្យនិងនីរតីមិនត្រូវគ្នាគាត់ដើរឃោសនា ខ្ញុំថាអត់ធ្វើរឿងនេះជារឿងស្លាប់បើចែឯងធ្វើទៅ ដល់ពេលនេះគាត់ដើរទៅមោៗ ដល់នេះអាដែងចាប់សម្លាប់ចោលទៅជាមួយតាក្រុក ។

ដារ៉ា ៖ អរ! ជាមួយតាក្រុកបាទឮឈ្មោះតាក្រុកដែរ ។

បណ្ឌិតៈ តាក្រុកគណៈឃុំពាយ័ព្យ ក្រោយមោក្រោយឈ្មោះពួកប៊ុ សន នោះ មុនដំបូងគេធ្វើអញ្ចឹងមុនដំបូងគេយោធាកាន់ ប៊ុនសននោះយោធាទេប៊ុនតែគេដាក់ចាត់តាំង យោធាមានឈ្មោះមានឈ្មោះ អាមួយដែលចាប់បងខ្ញុំនោះឈ្មោះ ឈ្មោះ សាអែម មុនដំបូងយោធាគេមោគ្រប់គ្រងអ្នកស ដល់ក្រោយមោបានគេរៀបខាងរដ្ឋបាល នេះគេរៀបពួកតាក្រុកនិងជន ។

ដារ៉ា ៖ ហើយនៅក្នុងភូមិពូវាមានការកេណ្ឌជាកម្លាំងប្រជាជន ឬក៏យុវជនអីទៅលើកទំនប់ត្រពាំងថ្មទេ?

បណ្ឌិតៈ ទៅ មាន ប៊ុនខ្ញុំមិនដឹងថាពីណាគេទៅខ្លះខ្ញុំអត់ដឹងទេ ។

ដារ៉ា ៖ ការកេណ្ឌហ្នឹងបានទទួលផែនការពីណាមោ?

បណ្ឌិតៈ ទេអង្គការៗ ។

ដារ៉ា ៖ បើឮថាពាក្យអង្គការចឹងអ៊ំគិតថាអ្នកណាជាអង្គការកាលហ្នុង?

បណ្ឌិតៈ ខ្ញុំមិនដឹងថាអ្នកណាទេ បើសព្វថ្ងៃមានណាមានតែប៉ុល ពតហ្នឹងអង្គការ ។

ដារ៉ា ៖ មានសំដៅថា ពេលឮថាអង្គការសំដៅទៅលើយាយ ថែម ទេ?

បណ្ឌិតៈ ពីព្រោះកាលណោះគេធំហើយ ខ្ញុំមិនហ៊ានសំដៅតាណា ថាអង្គការដាក់ទិសឲ្យលើកទំនប់តែខ្ញុំមិនដែលទៅលើទេ ច្រើនតែជាពិសេស ដែលតែច្រើនដូចបងប្អូនយើងមោពីភ្នំពេញ

ជមៀសម៉ោនេះ ជួនកាលគ្នាមានគ្រួសារចេះទៅ នៅក្មេងដូចប្អូនឯងចេះទៅ បើអ្នកខ្លះដែលគ្នាប៉ិននិយាយប៉ិនចេះចុះទៅបាននៅទៅ ហើយខ្លះទៅគ្នាមិនសូវប៉ិនមិនសូវដឹងអីទៅៗ ។

ដារ៉ា : នៅក្នុងភូមិពូហ្នឹង កាលដែលម៉ោធ្វើការកេណ្ឌប្រជាជនទៅលើកអាងនៅក្នុងអាងនៅទំនប់ត្រពាំងថ្មនៅក្នុងឆ្នាំណាទៅពូ?

បណ្ឌិតៈ ឆ្នាំ១៩៧៧ តែបានយើងចប់ភ្លាមបានម៉ាឆ្នាំធ្វើស្រែរួចគេចាប់លើកទំនប់កំបោរស្រែះកំបោរស្រែះរួចលើកអាពីរនេះ ភ្លោះពីរនេះ លើកពីរនេះរួចអ្នកដែលសល់ប៉ុន្នានទៅអ្នកដែលសល់ប៉ុន្នានទេ អ្នកដែលមេនៅនេះងាប់អស់ហើយ បានខ្ញុំថាអ្នកក្តោបក្តាប់ងាប់ម៉ត់ដែលអ្នកទៅក្តោប់ក្តាប់ទំនប់មាននារីមាន ប៉ិនគាត់នៅម្នាក់ នេះគាត់ខាងភស្តុភាទេប៉ិនគាត់ឈឺហើយ គាត់នៅអាមេរិកទើបម៉ោ ម៉ោគាត់បានប្រពន្ធចុងនៅបាត់ដំបង គាត់ឈឺដឹកយកទៅពេទ្យ គាត់និយាយក៏ម្យ៉ាង ហ្នឹងបើនិយាយឲ្យចំគាត់ធ្វើឃាតពួកតាវ៉ាល់អាទំនប់នេះលើកសម័យយើងពួកនេះ ទេពួកពាយ័ព្យ ពួកនីរតីវាអត់មានម៉ោធ្វើ ពួកនេះឯងវាម៉ោវ៉ៃរបបដូចថាវាម៉ោទូទាត់គ្នា សម្លាប់គ្នាទៅ ។

ដារ៉ា : ចុះអាងត្រពាំងថ្មហ្នឹងអាហ្នឹងលើកដោយក្រុមពួកខាងណា ពួកនីរតីអ្ហេះ?

បណ្ឌិតៈ អត់ទេពួកពាយ័ព្យហ្នឹងទេ ។

ដារ៉ា : ប៉ុន្តែគ្រាន់ថាមិនទាន់ហើយ?

បណ្ឌិតៈ មិនទាន់ហើយ ។

ដារ៉ា : កាលហ្នឹងក្នុងភូមិពូបើនិយាយទៅមានមនុស្សប៉ុន្នាននាក់ទៅលើកអាងត្រពាំងថ្ម?

បណ្ឌិតៈ ខ្ញុំក្តាប់មិនបានទេរឿងនេះអ្នកភូមិណាទៅខ្ញុំក្តាប់អត់បាន ខ្ញុំកាលសម័យនោះហៅថាមានតួនាទីទេ តែខ្ញុំតែពីរនាក់ក៏គេមិនឲ្យទៅអង្គុយនិយាយគ្នាពីរបីនាក់ទេ ព្រោះថាធ្វើការរៀងខ្លួនល្ងាចឡើងម៉ោផ្ទះ តែខ្ញុំចេះតែនឹកឃើញ ខ្ញុំតាមដានមើលតាំងពីសម័យយើងសង្គមចាស់បើនិយាយទៅតាមដានខ្មែរក្រហមហ្នឹងវាជាប់ពាក់ព័ន្ធ ដូចថាមានបងមួយគាត់ឲ្យទ្រស្តីរៀនទៅណា ហើយចូលចិត្តអានេះផងក៏ល្អគេមែន វណ្ណៈមិនឲ្យមានវណ្ណៈ ស្មើ បានម៉ោយើងអាចធ្វើរបបមួយទន់ រដ្ឋគេកំណត់ ហើយសេវាធំៗរួមភេទអីរដ្ឋអ្នកក្តាប់ ម្ល៉ោះហើយយើងតែវា អាអ្នកធ្វើដែលអ្នកក្រវាចេះតែទៅវាយល់ហើយ វានិយាយណាពួកគាត់ពួកមេខ្មែរក្រហមមុនៗសុតតែជាសាស្ត្រាចារ្យ មិនៗៗធ្វើជាគ្រូបង្រៀន បងប្អូនខ្ញុំប៉ុន្នា

នាក់ដែលនៅគ្រូបង្រៀនដែរ ខ្ញុំចេះតែថានៅប៉ុន្មានថ្ងៃទេរត់ខ្ទេចអស់ឥឡូវ (ពុសម្ដេងរំខានស្ដាប់មិនបាន) គាត់ទៅបង្រៀនម៉ាឆ្នាំហើយ....ឲ្យកូនសិស្សបង្រៀននៅសៀមរាប ។

ដារ៉ា : កាលហ្នឹងពេលដែលយាយ ចែម ចុះម៉ោប្រជុំម្ដងៗចឹងពូ ពូអាចពិនិត្យមើលឃើញថាស្ថានភាពម៉េចដែរ ដូចថាទឹកមុខគាត់មាំកាច ឬក៏ប្រជាជនមិនហ៊ានមើលមុខយ៉ាងម៉េច?

បណ្ឌិតៈ ទឹកមុខយាយ ចែម មុខគាត់មិនសូវញញឹមទេមុខគាត់ហ្នឹង បើនិយាយញញឹមនិយាយម៉ោស្លូតទេ សម្ដីស្លូតប៉ុនរឿងការងាររម៉ឹងម៉ាត់បណ្ដោយ ដូចកាចបណ្ដោយ ប្ដីគាត់ជីខ្ញុំមិនស្គាល់ ។

ដារ៉ា : ប្ដីគាត់ឈ្មោះអី?

បណ្ឌិតៈ ប្ដីគាត់ យ៉េង ។

ដារ៉ា : យ៉េង?

បណ្ឌិតៈ ប្ដីគាត់គណៈស្រុកសេរីសោភ័ណ ។

ដារ៉ា : គណៈស្រុកសេរីសោភ័ណ?

បណ្ឌិតៈ អានេះវាធ្លាប់រត់ទៅជាមួយគេមួយរត់ទៅបាត់ ដល់ជម្លៀសទៅៗនៅតាមគេ គេកៀទៅ ។

ដារ៉ា : ទៅតាមយាយចែម ក្រុមយាយចែម?

បណ្ឌិតៈ រត់ម៉ោវិញ កាលហ្នឹងទៅដល់ដើងភ្នំ ប៉ុនវានៅលីវអាយុ១៧ ១៨ ។

ដារ៉ា : ចុះពី៧៧ទៅទៀតពូមានហេតុភេទអីយ៉ាងម៉េចតទៅទៀត?

បណ្ឌិតៈ ៧៧ទៅទៀតវាចប់ហើយចប់ដូចខ្ញុំថាផ្ទៃក្នុងរបស់ប៉ុល ពតវាវង្គោះវង្គើហើយ ដូចថាវាកាប់សម្លាប់គ្នាទៅវាមិនទុកចិត្តគ្នាតិចម៉ោបានវាមានរឿងកាប់សម្លាប់បន្ត ម្ល៉ោះហើយគេបំបិទពិអាពួកយោធាចាស់ដឹងតែហៅទៅហើយវៃអស់ពួកយោធាចាស់ ខាងរបបនោះដូចគ្នាស្រាប់តែម៉ោដល់ប្រធានភូមិនេះម៉ាសារ ម៉ោដល់ប្រជាជនប៉ះអស់ សឹងថាឲ្យតែប្រុសវាជាប់និន្នាការទាំងអស់ អាខ្លះវាមានមេដប់ខ្លួនអាអីណា យើងខ្លាចគេវៃដោះៗយើងចេះតែប្រាប់ប្រធានភូមិ ដាក់ឯកសារទៅចេះតែស្មើរ ដល់បងប្អូនយើងម៉ោពីភ្នំពេញចេះទៅលាក់ប្រវត្តិរូបបានរស់ទៅ តែបើលាក់មិនបានដឹងថា អើយើងថាយើងធ្វើប៉ូលីសក្រុងខ្ញុំមានក្មេងខ្ញុំ ម៉ាក្រុមខ្ញុំមានគេហៅសួរចឹងដែរតើ ហៅសួរប្រវត្តិរូប បងឯងធ្វើ? ខ្ញុំធ្វើប៉ូលីស ខ្ញុំចេះតែដាក់អើចុះម៉ោដេកណេះហើយនោះ ដាក់មួយទៀតទៅ ។ ខ្លះធ្វើកម្មករខ្ញុំចំនាំមើលចុងក្រោយរស់ អ្នកដែលលាក់ប្រវត្តិរូបបានរស់ តែឲ្យតែមាននិន្នាការសម័យ

នោះ ដឹងតែអស់ បើប៉ូលីសទាហានអស់ដូចតែគេ ខ្ញុំនេះបងជីដូនមួយប្រពន្ធខ្ញុំនាំបាំពាសនេះ នៅជិតនេះ យកប្តីទៅ យកប្តីជាប៉ូលីសជាទាហាន ។

ដារ៉ា : ហ្នឹងសុតតែក្រោមការគ្រប់គ្រងរបស់យាយ ចែម ពេលហ្នឹង?

បណ្ឌិតៈ អាពេលនោះ បាទពេលនោះ យាយចែម ។

ដូចមួយនៅព្រែកកាំនោះប្អូនជីដូនមួយរបស់ខ្ញុំនោះគេចាប់យកទៅ ។

ដារ៉ា : ឈ្មោះអីហ្នឹង?

បណ្ឌិតៈ ឈ្មោះ ចាន់ ពេទ្យសត្វ ។

ដារ៉ា : ពេទ្យសត្វ?

បណ្ឌិតៈ ពេទ្យសត្វសម័យយើងពាន្នាំ ប៉ុនពេទ្យសត្វខាងពាយ័ព្យ ។

ដារ៉ា : យាយចែមម៉ោចាប់ផ្ទាល់ម៉ង?

បណ្ឌិតៈ ចុះគាត់មេហើយ ។

ដារ៉ា : អញ្ចឹងទីតាំងមូលដ្ឋានរបស់យាយចែមនៅណា?

បណ្ឌិតៈ ភ្នំលៀប ។

ដារ៉ា : នៅភ្នំលៀប គ្រប់គ្រងម៉ាស្រុកព្រះនេត្រព្រះ?

បណ្ឌិតៈ ម៉ាស្រុកព្រះនេត្រព្រះ ឃើញមុខគាត់ក្នុងទូរទស្សន៍ គេចាប់គាត់ហៅ គាត់ឆ្លើយថាគាត់មិនទទួលស្គាល់រឿងសាលាក្តី គាត់ថាមិនទទួលកំហុស ហ្នឹងជារឿងរបស់គាត់ គាត់និយាយក្នុងទូរទស្សន៍ យាយចែមឃើញមុខ សព្វថ្ងៃគាត់នៅធ្លើយុំ ។

ដារ៉ា : ដល់ចឹងពូ ចុះក្រុមគ្រួសារពូបង្កើតម៉ង ជាប្តីជាប្រពន្ធឬកូនអីមានបាត់បង់ជីវិតអីដែរសម័យខ្មែរក្រហម?

បណ្ឌិតៈ មានបងបង្កើត បងប្អូនជីដូនមួយ ក្មួយអីទៀត បើថាក្នុងក្រុមគ្រួសារខ្ញុំ មានម្តាយក្មេក ។

ដារ៉ា : កាលហ្នឹងការហូបចុកអីនៅក្នុងភូមិពូយ៉ាងម៉េចដែរ?

បណ្ឌិតៈ រាងតឹងតិច បើមិនចេះទេអត់ទៅ ខ្ញុំនិយាយតែម៉ាត់ទេ ។

ដារ៉ា : ភាគច្រើនអ្នកស្រុកអ្នកភូមិរស់បានទាល់តែចេះរស់?

បណ្ឌិតៈ ទាល់តែចេះរស់ ។ តែបើតាមខ្ញុំចំណាំមើលអ្នកណាដែលចេះប៉ិនអែបអបជាមួយវា ពួកនឹរតីរស់ តែបើអ្នកណាប្រឆាំងជាមួយវាថាពួកខ្មាំង ដល់នេះវាចាប់ទៅវាមើលឃើញ ហើយខ្ញុំក៏ជាប់និន្នាការដែរ គេម៉ោហៅដែរ ប៉ុនដូចថាវាតាមមើលឃើញខ្ញុំធ្វើរហូត ព្រោះខ្ញុំជាប់និន្នាការអាធ្វើប្រធានក្រុមមុន កាលពីដើមម៉ោដែលខ្ញុំម៉ោនៅភូមិហ្នឹងជំនាន់ហ្នុង មើល

ទៅឃើញតែខ្ញុំធ្វើការមិនសូវនេះយកចិត្តទុកដាក់ មិនសូវនៅផ្ទះទេ ធ្វើស្រែ ចុះបើខ្ញុំអ្នកស្រែស្រាប់ហើយ ភ្ជួរៗហើយមែនធ្វើម៉ាសមកម្ចាំឲ្យម៉ារស់ៗណា ដល់ហើយថាឲ្យធ្វើប្រធានក្រុមទៅ ភ្ជួរ ។

ដារ៉ា : ហើយម៉េចបានគេចផុតបានចុះ

បណ្ណិតៈ គេចផុតបានបើដល់នីរតីម៉ាស្រាវប្រវត្តិរូបខ្ញុំ ដល់ថ្ងៃវាម៉ាហៅខ្ញុំនោះហៅយកខោអាវម៉ាហៅយកខោអាវ៣នាក់ ហៅខ្ញុំឲ្យយកខោងអាវ យកខោអាវខ្ញុំដឹងមុនថាខ្ញុំដឹងមុនហៅម៉េយកខោងនៅកន្លែងនោះ ពួកនីរតីខ្ញុំនៅសាបវ៉ា អាពួកឈ្លបនោះ ដល់នេះប្រើឲ្យខ្ញុំទៅហៅថាយកខោអាវ ហើយមានមួយទៀតឈ្មោះ ប្រូ នោះ សព្វថ្ងៃនៅរស់ម៉ាតាមសុំតែខ្ញុំ មេក្រុមសាបនេះគេនៅកាន់ អ្ហូ! ខ្ញុំទៅផង អ្ហូ! សុំចូលៗៗយកខោអាវដល់ទៅឃើញខ្ញុំម៉ាផ្ទះវិញគេច ថ្ងៃម៉ាហៅខ្ញុំទៅ ចាប់នៅក្នុងភូមិនេះអស់៣ ទៅយករូបយប់ឡើងគេម៉ាចាប់ នេះប្ដីមីនេះ ។

ដារ៉ា : ពួកអ្នកម៉ាចាប់ហ្នឹងច្រើនតែដា?

បណ្ណិតៈ ស្រីៗគ្នាវាប៉ុន្មាននាក់វាប្រមូលគ្នាដូចថាម៉ាក្នុងសហករណ៍ចេះទៅ អត់មានយោធាទេស្រីៗពួកវា ប្រុសតែម្នាក់ពីរនាក់អីប៉ុណ្ណោះ គេហៅថាភូមិបណ្ដាញគេ ក្នុងភូមិនេះបណ្ដាញអ្នកចេះដឹងម្នាក់ៗ ភូមិនេះហៅទៅម៉ាវិញគេដើរចាប់ ។

ដារ៉ា : កងយាយចែមហ្នឹង?

បណ្ណិតៈ កងយាយចែម ដល់ខ្ញុំហៅទៅខ្ញុំអត់ទៅ ។

ដារ៉ា : ចុះពូអត់ទៅចឹងមិនប្រឆាំងនឹងអង្គការ?

បណ្ណិតៈ ចាំមើលបានខ្ញុំអត់ទៅ ខ្ញុំដាក់ចិត្តដែរណា ខ្ញុំដាក់ចិត្តថាបើទៅក៏ងាប់មិនទៅក៏ងាប់សុខចិត្តងាប់ក្នុងផ្ទះចុះ ដាក់ចិត្តអញ្ចឹង ឲ្យងាប់នៅហ្នឹងកន្លែងនេះឲ្យប្រពន្ធកូនដឹងថាងាប់ហើយកុំឲ្យពិបាកសង្ស័យ ដូចសព្វថ្ងៃខ្ញុំដូចមានអ្នកខ្លះខ្ញុំគិតទៅ ប្ដីអារុណាងាប់ហើយថារស់ៗ អើសុខចិត្តងាប់ទៅចុះគេយកទៅវៃហើយងាប់ហើយ ខ្ញុំរៀបព្រលប់ៗឃើញយាយពីរនាក់គាត់យកស្លឹកចេកយកម៉ាចែកពួកប្រធានសហករណ៍ ប្រធានគណៈឃុំ ឈ្មោះទិតមោកដល់ហើយខ្ញុំហៅទិតមោកចូលផ្ទះរបស់ខ្ញុំ គាត់ក៏ចូល ដល់ហើយខ្ញុំប្រាប់ថា មើលប្រពន្ធកូនខ្ញុំផងណាខ្ញុំទៅហើយ ដល់ពេល អ្ហូ! ឈប់សិនអញម៉ាម៉ិញទេម៉ាពីកន្លែងពួកវាណាគាត់ម៉ាកន្លែងពួកនីរតី យើងមានថ្ងៃគេវៃតែម៉ាយប់នេះទៀតទេ អ្នកដែលជាប់ពាក់ព័ន្ធ

ឈ្មោះ វៃតែម៉យប់នេះទៀតទេអ្នកណាហ៊ានអត់បាន ហើយគាត់បូព៌ានោះម៉ោប្រាប់ខ្ញុំ ថាខ្ញុំគេចមើលសិនទៅគេចរួចគេចទៅ ។

ដាវ៉ា : ឡុផុតម៉ាយប់ហ្នឹង?

បណ្ណែតៈ ដល់នេះខ្ញុំទៅប្រាប់បងប្អូនខ្ញុំឲ្យរត់គេចក្បែរៗ ទៅសិនចាំមើល ដល់ព្រឹកឡើងឃើញថា យោធាម៉ោប្រកាសថាមាការលើកលែងទោស អ្នកជាប់និន្នាការទាហាន អ្នកមានឈ្មោះអី អត់អីទេនៅធ្វើការធម្មតា នោះឈប់វៃហើយ ប៉ុនអាការឈប់វៃនោះវាគ្រាន់តែមើល ឃើញដូចត្រីក្នុងអន្ទ្រុតអញ្ចឹង តាមដានធ្វើការឲ្យវា មិនហ៊ានធ្វើអីខុសទេ ហើយមានអី យើងត្រូវចេះយកចិត្តវា យើងចេះសម្របនឹងវាយើងកុំប្រឆាំងជាមួយវា តែប្រឆាំង ដេកហើយ ។ ស្រីៗដូចថាខ្ញុំនិយាយ ដូចថាស្រីៗច្រើនទៅក៏វាដូចប្រាល វាដូចជាកម្លាំង កាយ វៃយវា ដូចថាវាស៊ីឆ្អែតទៅ វាព្ធដល់បងប្អូនយើងទៅវាហឺទៅ ជាពិសេសអ្នកដែល មានកូនកំលោះគឺតែងតែម៉ោចូលផ្ទះ ម៉ែក្មេកខ្ញុំគាត់មានកូនកំលោះ ស្រីៗនោះចូលចិត្ត ណាស់ បើសិនជាត្រូវវាឲ្យស៊ីអស់ បើយើងចេះផ្គាប់ផ្គុនវា វាចូលចិត្តអ្នកមានកូនប្រុសពួក វាស្រីៗ ។

ដាវ៉ា : ហ្នឹងម៉ោក្រុមយាយវែនហ្នឹងសុទ្ធតែស្រីៗ?

បណ្ណែតៈ ក្រុមយាយចែម ។

ដាវ៉ា : ក្រុមយាយចែម?

បណ្ណែតៈ បាទ!

ដាវ៉ា : សុទ្ធតែស្រីៗ កម្មាភិបាល?

បណ្ណែតៈ ប្រុសតិចណាស់ ។

ដាវ៉ា : ប្រុសតិចវិញ?

បណ្ណែតៈ បាទ! ប្រុសតិច ក្តាប់ពួកខ្ញុំស្រីទាំងអស់ ទាំងគណៈឃុំស្រី ទើមានអាប៉ិ លន់ ក្រោយ ដែលជិតចប់ហើយឈ្មោះ លន់ ថានៅភ្នំពេញ ។

ដាវ៉ា : ចឹងពូ ដល់ៗ អាហ្នឹងចូល៧៨ហើយពូណោះ?

បណ្ណែតៈ បាទ! ចូល៧៨ហើយ អាចាប់វៃនោះចូល៧៨ហើយអានោះ ព្រួសប្រាស់ខាងខ្ញុំក៏រត់ អីក៏រត់ ជិតចប់ហើយប្រហែល៣-៤ខែ ៤-៥ខែចប់ ចប់ដល់ភូមិយើងខែនេះខែ៥ ៦ ៧នេះចាប់ផ្ដើមចាប់មនុស្សវៃហើយ ពួកបងប្អូនដើរចាប់តាមវាលតាមអី ហៅវៃៗរត់ទៅ ថៃទៅអី ចប់ប៉ុន្មានខែទៀតទៅដលខែប៉ុន្មាន ឆ្នាំ៧៩ ។ ៧៨គាត់ស្លាប់ច្រើន

ស្ដាប់មែនមាននិន្នាការទាហានទេ អានោះស្ដាប់ដូចថាវាម៉ាបក្ស អ្នកបម្រើបក្សមុន អ្នកណាដែលបម្រើបក្សមុន ។

ដាវ៉ា ៖ ដូចថារបៀបម៉ោបោសសំអាតពួណោះ?

បណ្ឌិតៈ បាទ! បោសសំអាអស់អាលីង អ្នកណាសល់រត់ ភូមិខ្ញុំរត់ច្រើនណាស់រត់ទៅអស់អាលីង មនុស្សប្រុស នៅសល់តិចណាស់ នៅតែខ្ញុំ បើបង្កើយត្រឹមខ្ញុំម៉ត់ នៅតែមនុស្សស្រី វាំងការរត់ទាំងខ្ញុំមានបីបួននាក់ទៀតប៉ុណ្ណោះឯង អស់ហើយៗ បើនៅៗតែពួកបងប្អូនពី ភ្នំពេញដែលផ្ទះនោះនៅធ្វើការតាមរោងបាយ ហើយគាត់មាននិន្នាការអី ។

ដាវ៉ា ៖ ចឹងមានន័យថាពេលដែលក្រុមយាយ ថែម ម៉ោៗសុទ្ធតែក្រុមស្រីៗភាគច្រើន?

បណ្ឌិតៈ ម៉ោសុទ្ធតែស្រីភាគច្រើន ។

ដាវ៉ា ៖ ហើយដល់ពេលជនរងគ្រោះដែលស្ដាប់ក្នុងរបបដែលគ្រប់គ្រងដោយយា ថែម ហ្នឹងសុទ្ធតែ ប្រុសៗវិញចឹង?

បណ្ឌិតៈ ប្រុសៗច្រើន ។

ដាវ៉ា ៖ វាទំនាស់ម៉េចជាមួយប្រុសស្រីហ្នឹង?

បណ្ឌិតៈ អានេះដូចខ្ញុំនិយាយចឹង អាផ្នែកប្រុសៗម៉ោយើងម៉ោដូចអាពួកពាយ័ព្យនោះគាត់មិនឲ្យធ្វើ ដូចប្រធានក្រុម ប្រធានកងចឹង ដល់ពេលវាម៉ោនៅនេះវានៅតាមដានស្អីយើងអត់ដឹងទេ ហើយបើយើងក្មេង ដូចថាយើងប្រកាន់បក្សតឹងអ្វាស ប្រកាន់តឹងទៅយើងត្រូវតែចាប់ គាត់ ដល់ពេលវាក្ដាប់បានរួចរាល់វាចាប់ផ្ដើមចាប់មេស្រុក ចាប់មេភូមិអី ចាប់ម៉ោដល់ មេភូមិមេអីទៅ ។ ហើយភូមិខ្ញុំឈ្មោះ ថែមៗ នារី ថែម ពួកពាយ័ព្យហ្នឹងរត់ទៅត្បូវអីទៅ នារី រ៉ែម មួយពួកពាយ័ព្យរកចាប់រត់ ឈ្មោះ យឹម មួយគេថាអរទៅរត់ ប៉ុនមិនដឹងរត់រួច ផុតម៉េចទេ ងាប់បាត់អស់ហើយ ឮថារត់ទៅត្បូង ។ ហើយដូចខ្ញុំៗអត់ប្រកាន់ទេខ្ញុំនៅនេះ អាមួយដែលម៉ោពីកាណាដា វាចេញនោះវាម៉ោលេងជាមួយយើង ទៅក្រៅ សួរសុខទុក្ខ វាម៉ោលេង នេះនៅផ្ទះនេះ ។ ដូចខ្ញុំនេះ វាថាបងឯងអត់រត់ទេនៅគិតអី អានោះវាចេះ គ្រាន់ដែរវានៅក្មេងជាងខ្ញុំ វានៅភ្នំពេញ ហើយម៉េចបានចេះតែទ្រគេកើត វាសួរខ្ញុំ វាហ៊ានសួរតែខ្ញុំមួយ ទេ វាទុកចិត្តខ្ញុំ ដូចថាវាទុកចិត្ត ខ្ញុំឃើញនីរតីម៉ោក៏ត្រូវ ឃើញពួក ពាយ័ព្យម៉ោក៏ត្រូវ ទៅទាស់ម៉េចយកតែម៉ារស់ទៅ ថាម៉េច ទោះបីថាវាធ្វើអី ដូចថាដក ខាងជើងចេះណា វាដាក់ទិសយើងទៅស្រូវទឹកត្រឹមណោះក៏ទៅដែរ លុយទឹកទៅស្ទួងខែ វស្សា ទៅដក់អីនៅជងស្ទឹង ដកម៉ោអីជើង ចុះមុជម៉េចកើតទឹកស្មើណោះពួកម៉ោពីភ្នំពេញ

បេះហែលទឹកប៉ុន្មាន សុទ្ធសាធ មិនស្គាល់ដើមស្រូវផងក្មេងៗ ទៅដក ធ្វើម៉េចបាន ធ្វើម៉េចធ្វើ អ៊្ហា! ដកជើងស្ទូងនឹងជើង ចុះដកពីទឹកត្រឹមនេះទៅស្ទូងទឹកប៉ិនណេះ ហើយខ្ញុំបេះតែចង់ដឹងថាម៉េចបានជាវាធ្វើចឹងកើតម៉េច បានខ្ញុំថាអានេះជារឿងរបស់វា រឿងនេះហើយបានវាទៅ អ្ហូរ! បេះហើយ បានក្តាប់សេដ្ឋកិច្ចមិនបានមែនបានវាទៅភាគតិច យកតែបរិមាណអត់ចុះម៉ោមើលអាកន្លែងចុះដិតដល់ ពីថ្នាក់លើម៉ោ ពីនាយករដ្ឋមន្ត្រីម៉ោវាមានបានម៉ោមើលធ្វើការខាងក្រោមបានប៉ិនណា បេះតែស្ទូងយកតួរលេខដាក់ផែនការវិប លើងផែនការគណៈឃុំមិនដាក់ផែនការទៅស្រុក ម៉ាស្រុកគេធ្វើស្រែបានប៉ុន្មានហិកតាយករបាយការទៅក្រសួង ខ្ញុំនិយាយតាមលំដាប់ដូចសព្វថ្ងៃឡើងទៅក្រសួង ក្រសួងឆ្លើយភ្លាម ម៉ាហិកតាបានប៉ុន្មានតោន គេថាម៉ាតោន៣តោនគេថាវើម៉ាតោនកន្លះទៅពីរតោនចឹងទៅ ទឹកដីប៉ិនណេះ ប្រជាជនប៉ិននាក់ៗ បូកសរុបម៉ោស្រូវធ្វើបានប៉ិនណេះ ស្រូវធ្វើបានប៉ិនណេះ ម៉ាហិកតាបានប៉ុន្មានតោន ទុកស្រូវឲ្យអ្នកឯងស៊ីសល់ប៉ុន្មានជូនរដ្ឋ អានេះហើយបានត្រូវខាតបង់តំបន់៥រងគ្រោះ យកតែស្ទូង អាស្រែប៉ិនណេះអីខ្ញុំទៅ ឃើញស្ទូងៗ ហើយខ្ញុំនៅក្តាប់ម៉ាក្រុមបេះទៅ ក្រុមពួកពាយ័ព្យនេះទៅ ហើយពួកនិរតីក្តាប់ម៉ាក្រុមពីរបីក្រុមគ្នាវា ដូច មាស ផុន ចឹងៗ ដល់ខ្ញុំឃើញអញ្ចឹងវាស្ទូងម៉េច ស្ទូងម៉ាថ្ងៃប៉ុន្មានហិកតាណោះ ខ្ញុំបេះតែឆ្ងល់វា ខ្ញុំនេះសួរប្រពន្ធខ្ញុំ ប្រពន្ធខ្ញុំពោះធំ ខ្ញុំទៅស្ទូង ខ្ញុំខ្លាចប្រពន្ធខ្ញុំពោះធំ វាស្ទូងម៉ាថ្ងៃម៉ាហិកតា រួចថ្ងៃហ្នឹងដើរទៅលប ចុះបើយើងស្ទូវវាមានរបៀបរបបឲ្យបានស៊ី ដល់វាស្ទូងទៅបេះតែប៉ាតណាៗ រំលងប៉ិនណេះៗដូរ អាងតែគ្នាឯងស្របតាមគេទៅ ធ្វើម៉េចឲ្យតែបានសរសើរ ថាខ្ញុំធ្វើមិនបានដូចបងប្អូនធ្វើជើងទេ ស្ទូងបានប្រពន្ធខ្ញុំពោះធំចឹងទៅទទួលបន្ទុកឲ្យគ្រប់ផែនការ តែខំឯងអ្នករងគ្រោះខ្លាច ប្រពន្ធខ្ញុំពោះធំទៅស្ទូង ដល់ខ្ញុំយកប្រពន្ធពោះធំទៅស្ទូង យើអត់សូវពិបាកហៅគេប្រើជួយស្ទូងម៉ាក្រុមគេឃើញប្រពន្ធខ្ញុំពោះធំទៅស្ទូងហើយ ចង់អ្នកឯងល្មមៗក៏ទៅដែរអត់ហ៊ានឈប់ទេឲ្យរួចផែនការគេ ហើយចឹងបានខ្ញុំបេះតែត្រូវ ចឹងបានខ្ញុំថាផែនការរបស់ធ្វើដល់ទៅ៣ស្រុកហើយនៅតំបន់៥ ហើយស្រែស្រុកនេះទឹកខែវស្សាទៅម៉ោពីរថ្នោល ម៉ាថ្នោល ហើយពីសង្គមចាស់សំប៉ានដឹកស្រូវរាប់រយបាវម៉ោដល់នេះម៉ោដល់នឹងមាត់ទឹក ហើយទៅប្រើទឹកសន្ទូងស្រែពង្រោះ ធ្វើស្រែពង្រោះ ហើយតំបន់វាលទន្លេ ទឹកទន្លេដល់យើងទៅស្ទូងម៉េចកើត ។

ដារ៉ា : អាហ្នឹងគេហៅថាធ្វើស្រូវឡើងទឹកនោះណា?

បណ្ឌិតៈ បាទ! ទឹកទន្លេ ខែទឹកទន្លេដូចខ្ញុំថាប៉ះឆ្នាំណាផុតសមុទ្រមើលទៅជាប់មេឃទៅដល់ដងស្ទឹង ។

ដារ៉ា ៈ ដងស្ទឹងអីហ្នឹង?

បណ្ឌិតៈ ស្ទឹងមង្គលបូរី ។

ដារ៉ា ៈ ហើយចឹងពូដឹងរឿងរ៉ាវមឹង ចែម ដែរ?

បណ្ឌិតៈ បាទ! ខ្ញុំពេលកាលដែលគាត់មុននឹងរត់ កាលដែលឯងធ្វើការស្ទូងស្ទឹៗ នេះគឺគាត់មិនដាក់ផែនការ ដល់ពេលគាត់ម៉ោដាក់ផែនកាស្ទូងម៉ាហិកតាឲ្យបានប៉ុន្មានៗ គាត់ម៉ោធ្វើការចាប់ពួកក្រុម ហើយដូចខ្ញុំនេះជាប់ក្រុម ពួកមូដ្ឋានចាស់មានពីរនាក់ អ្នកមូលដ្ឋានចាស់មានជាប់ប្រធានក្រុមពីរនាក់ក្រោយពីពួកពាយ័ព្យគេរលំរលាយទៅនៅហ្នឹង ខ្ញុំគែហៅខ្ញុំទៅសួរប្រជុំខ្ញុំថា ចុះខ្ញុំឈប់ធ្វើការគេឈប់ប្រើនោះ គេយកគ្នាគេប្រើ ហើយខ្ញុំសួរគេនៅក្នុងអង្គប្រជុំថាខ្ញុំឈប់ធ្វើការដែរ វ៉ាថាអត់ឲ្យឈប់ទេនៅតែធ្វើ ដល់ធ្វើគេមានប្រើណា គេប្រើតែកម្លាំង ដល់នេះទៅគេមិនដែលរករឿងខ្ញុំទៅខ្ញុំអត់ដែលសតិអារម្មណ៍ ដល់នេះទៅវ៉ាហៅខ្ញុំប្រើនៅក្នុងក្រុម ហើយប្រពន្ធខ្ញុំនៅវ៉ាឲ្យទៅនៅកិនស្រូវ ចឹងបានជាគ្រួសារខ្ញុំវ៉ាមិនដានដុននៅកន្លែងកិនស្រូវយើងអាចលួចអីខ្លះ ដូចថាគេផ្តាច់បបរយើងបានបបរ ។

ដារ៉ា ៈ អញ្ចឹងអាពេលដែលអាងត្រពាំងថ្មហ្នឹងយាយ ចែម គ្រប់គ្រងដែរ?

បណ្ឌិតៈ ទេសម័យនោះមានតែប្រុសៗទេ ក្រោយម៉ោបានយាយ ចែម អាងត្រពាំងថ្មដូចធ្វើមុ

ដារ៉ា ៈ ធ្វើមុនយូរហើយណោះ?

បណ្ឌិតៈ ធ្វើមុនម៉ាឆ្នាំ ជាប់ពីស្ទឹងលើកឆ្នាំ៧២-៧៣ ៧៨ចុង បើអាងត្រពាំងថ្មធ្វើមិនទាន់ចប់ទេក្រោយ ។ នៅស្ពានម៉េម៉ាយមួយនៅចោលគេហៅស្ពានម៉េម៉ាយ គេហៅស្ពានម៉េម៉ាយសព្វថ្ងៃគេចាក់សសររួចហើយ ចាក់ខឿនរួចហើយ ចាក់សសររួចហើយ បេតុងនៅបាត ។

ដារ៉ា ៈ ប្រុងធ្វើស្ពាន?

បណ្ឌិតៈ បាទ!

ដារ៉ា ៈ ឥឡូវទៅឥឡូវនៅ?

បណ្ឌិតៈ ឥឡូវនៅចំហរឆ្ពង គេហៅស្ពានម៉េម៉ាយសព្វថ្ងៃ ។

ដារ៉ា ៈ អាហ្នឹងខាងពាយ័ព្យទេអ្នកធ្វើ?

បណ្ឌិតៈ ពាយ័ព្យធ្វើ ដល់នីរតីម៉ោចាប់អាបិុមេសំណង់យកសម្លាប់ងាប់បាត់ ។ អានោះឲ្យតែមេសំណង់ធំៗគឺគេចាប់ ដូចការដ្ឋាននេះចាប់ ។

ដារ៉ា ៖ ចុងក្រោយចង់សួរយោបល់ពូដែរទាក់ទងរឿងយាយ ចែម ដោយសារគាត់និយាយថាពីរឿងការមិនទទួលខុសត្រូវដែលពូឃើញក្នុងទូរទស្សន៍ពូ ចុះចំពោះពូផ្ទាល់ពូយល់ឃើញយ៉ាងម៉េចដែរ?

បណ្ណុគះ ដូចថាវា ខ្ញុំឮគេនិយាយខ្ញុំថាហ្ហ៎! គេបញ្ឆោត បើថាយើងមិនធ្វើ បន្តពីលើម៉ោយើងត្រូវទទួលខុសត្រូវស្រុក ធ្វើម៉េចយើងអាចសម្រេចបាន និយាយហ្នឹងខ្ញុំស្តាប់ចំប៉ះសម្តេចនាយកគាត់លើកលែងទោស ធ្វើសមាហរណកម្ម កាត់ទោសតែប៉ុន្មាននាក់ ថ្នាក់ដឹកនាំខ្ពស់បំផុត ថាគាត់ធ្វើមែនអត់គាត់ទទួលដឹង ។

ដារ៉ា ៖ ពូមានអីចង់បន្ថែមទៀតទេដែលខ្ញុំអត់បានសួរអីហើយពីចង់ប្រាប់ពួកខ្ញុំ?

បណ្ណុគះ ប្រាប់អីទេ ប៉ុននឹកក្នុងចិត្តថា នៅពេលក្នុងការកាត់ទោសក្តី ពេលដែលឃើញដូចជាពន្យាពេលវែងគ្មានស្អីទេ វាដូចជា ឬគេធ្វើយ៉ាងណា ដូចថាយើងឃើញហើយថាគេកាត់ទោសតាឌុច ម៉ោពាក់ព័ន្ធជាមួយ ខៀវ សំផន, នួន ជា, អៀង ធីរិទ្ធ, អៀង សារី ខ្ញុំចង់ដឹងថា ជួយខ្ញុំប៉ុនហ្នឹងបានហើយ ខ្ញុំចង់ឆ្ងល់ថាហេតុម៉េចបានយូរ ។

ដារ៉ា ៖ តាមពិតទៅការបើកសវនាការបឋមទៅលើសំណុំរឿង០០២ ដែលមាន នួន ជា, ខៀវ សំផន, អៀង ធីរិទ្ធ, អៀង សារិ ជាជនជាប់ចោទហ្នឹងយើងនឹងចាប់ផ្តើមធ្វើនៅចុងខែនេះហើយពូ ធ្វើនៅថ្ងៃទី២៧ ខែ០៦ ខែមិថុនាយើងនេះពូ ចឹងពូអាចមើលតាមទូរទស្សន៍ ឬក៏ស្តាប់តាមវិទ្យុអីទាក់ទងនឹងសវនាការនេះ ហើយគេធ្វើឡើងរយៈពេល៤ថ្ងៃ ប្រហែលជា៤ថ្ងៃបើសិនជាសវនាការហ្នឹងអូសបន្លាយទៅមុខទៀតអត្ថាស ធ្វើ៤ថ្ងៃពីថ្ងៃ២៧ ដល់ថ្ងៃ៣០ ខែ០៦ អញ្ចឹងពូអាចមានឱកាសតាមដានសវនាការនេះ បើសិនជាមានស្រុកអ្នកភូមិពូសួរនាំរឿងតុលាការហ្នឹង គឺថាឥឡូវគេមានសវនាការហើយ ហើយគេចាប់ផ្តើមថ្ងៃ២៧ដល់ថ្ងៃ៣០ អាហ្នឹងគេហៅសវនាការបឋមសិនអត្ថាសពូ ។

បណ្ណុគះ ខ្ញុំឮឃើញថាឆ្លងកាត់ដល់សំណុំរឿង០០៣ បានខ្ញុំថាបើ០០៣ដល់ហើយដល់យាយ ចែម ដល់គណៈស្រុកហើយ ដល់នេះខ្ញុំចេះតែនឹកឃើញ តែដល់០០៤ដល់ហើយអាប្រធានសហករណ៍ណា គេហៅថាពាក់ព័ន្ធ ប៉ុននេះចេះតែទៅមុខហើយ ដល់យើងឃើញ០០១ មេដឹកនាំ ០០២.... ដល់០០៣ចូលដល់ចេះៗគាត់គណៈស្រុក ប៉ុនអាពួកពាយ័ព្យអត់នៅទេ អាពួកនោះកម្ទេចអស់ហើយអាអ្នកពាក់ព័ន្ធធំៗ ហើយចូលម៉ោដល់ខ្ញុំនេះហើយជាប់ម៉ោអាអ្នកដែលវ៉ៃកាន់ធ្វើបាបសម័យយាយ ចែម នោះមិនរស់ទេ ។

ដារ៉ា ៖ ចុះម៉េចបានយាយ ចែម រស់បាន?

បណ្ឌិតៈ អញ្ចឹងបានថាខ្ញុំឆ្ងល់ នេះថាគេធ្វើដោយប្រយោល បានថាអ្នកធ្វើតាមមិនកាត់ទៅកាត់អាអ្នក មានអាមួយនៅត្រង់ណោះស្តេហើយអានោះស្តេចហើយ អត់ស្គាល់ថាម៉ែឪបងប្អូនឯងអីទេដាក់ភូស១ៗពីរបី បងប្អូន ឪពុកធំឪពុកអីវាវៃ បើកូនក្មេងលួចស្រូវអង្ករគេចាប់ចងវាធាក់វាទាត់ ដល់ពេលចប់ក្លាមម៉ោបានតែម៉ាឆ្នាំពុថាទៅថៃគេចាប់វ៉ៃរត់វង្វេង វ៉ៃឡើងវង្វេង.... ភូមិនេះចែកជាពីរភូមិ ភូមិខ្ញុំកណ្តាលនេះចែកជាពីរភូមិ ព្រោះពួកវាបែងចែកជាភូមិវណ្ណៈ ចឹងបានវាចែកជាពីរភូមិ ម៉ាស្រទាប់លើឲ្យទៅនៅផ្ទះវែង ហើយស្រទាប់កណ្តាលនៅនេះ កណ្តាលសល់ប៉ុ អឿ ឈុន ដឹងថា ឈុន នៅគេចាប់ឲ្យពួកយាយចែមសម្លាប់ ហើយពួកហ្នឹងថាអ្ហើយខ្លាំង ខ្លាំងអីផាប់តែគ្នាអត់មានស្អីទេ ហើយអត់មានអីសម្រាប់ឲ្យកូនឲ្យចៅទេ បានដូចខ្ញុំជម្រាបទៅថាធ្វើព្រះទៅ តែបានជាអាអ្នកដឹកថ្នាក់នាំធំៗវាទៅជារូបខ្លួន វាបែរទៅជាវងគ្រោះអាអ្នកទទួលថ្មបាក់នេះឯង អញ្ចឹងបានខ្ញុំចង់និយាយថា អ្នកដែលទទួលទោសធំៗ អ្នកដែលបញ្ជាសុតតែគេមានស៊ីមានចុក បែរជាខ្លះបានធំទៀត ឧទាហរណ៍ ដូចគ្នាអាអ្នកទទួលរងគ្រោះគេប្រើស្រស់ៗ ផាប់ដោយជម្ងឺផាប់ដោយប្រតិកម្មផ្សេងៗអស់ទៅ ផាប់ពីរបីនាក់ដែរពួកដើងខ្លាំងៗអស់អាលើង បានខ្ញុំថាទៅអាលើងអស់ បានខ្ញុំថាអ្ហ៊ាធ្វើបាបគេបាន ប៉ុនដល់យើងនឹកឃើញចេះម៉ោ ពួកយាយប៉ុន្មានគាត់ ខ្ញុំសួរថាចុះបើអាអ្នកបញ្ជាគេម៉េចមិនផាប់ អាអ្នកធ្វើផ្ទាល់ដៃផាប់អស់ ខ្ញុំថាចឹងខ្ញុំនិយាយថាធ្វើប្រះនោះ ។

ដារ៉ា ៈ អញ្ចឹងខ្ញុំអត់មានអីសួរបន្ថែមទៀតទេ អរគុណច្រើនដែលបានផ្តល់បទសម្ភាសន៍ពូណាស់ ។

បណ្ឌិតៈ បាទ

«ចប់»